


# ការដាក់កម្រិតលើសេរីភាពក្នុងការបញ្ចេញមតិ ក្នុងវិស័យប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា

របាយការណ៍សង្ខេប លីកាដូ
ខែឧសភា ២០០៩

លីកាដូ
សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the
Promotion and Defense of Human Rights

# ការដាក់កម្រិតលើសេរីភាពក្នុងការបញ្ចេញមតិ ក្នុងវិស័យប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា

របាយការណ៍សង្ខេប លីកាដូ
ខែឧសភា ឆ្នាំ២០០៩


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENCE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្ស នៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរ :**

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែក ច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមអ្នកប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវិជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវិជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន ១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណៈជន អំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ បង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេត ដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ និងផលិតរបាយការណ៍ជាប្រចាំ ( ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទងៈ**


លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋានៈ អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទៈ (៨៥៥) ២៣ ៧២៧ ១០២ / ៣៦៤ ៩០១  ទូរសារៈ (៨៥៥) ២៣ ៧២៧ ១០២ / ២១៧ ៦២៦

អ៊ីម៉ែលៈ contact@licadho-cambodia.org  គេហទំព័រៈ http://www.licadho-cambodia.org/



**ឧបត្ថម្ភគាំទ្រពីស្ថានទូតអង់គ្លេសប្រចាំនៅទីក្រុងភ្នំពេញ**

ដោយប្រើប្រាស់មូលនិធិកម្មវិធីយុទ្ធសាស្ត្ររបស់ FCO

# មាតិកា

**១. បុព្វកថា ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១**

វិធីសាស្ត្រ និងវិសាលភាពនៃរបាយការណ៍ ---------------------------------------- ៤

**២. ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកម្ពុជា ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៥**

ស្ថានីយទូរទស្សន៍ ---------------------------------------------------- ៥

ស្ថានីយវិទ្យុ -------------------------------------------------------- ១០

សារព័ត៌មាន------------------------------------------------------- ២១

អ៊ីនធឺណិត --------------------------------------------------------- ២៤

**៣. ការគំរាមកំហែងលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ~~~~~~~~~~~~~~~~~~~~~~~~~~ ២៩**

ឃាតកម្ម ---------------------------------------------------------- ២៩

**តារាងការគំរាមកំហែង និងវាយប្រហារលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានៈ ខែមករា ឆ្នាំ២០០៨ ដល់ ខែមីនា ឆ្នាំ២០០៩**-------------------------------- ៣៤

**៤. អនុសាសន៍~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៥០**

# ១. បុព្វកថា

ធាតុពិត កម្ពុជាគឺជាប្រទេសមួយដែលពុំមានសេរីភាព ខាងប្រព័ន្ធផ្សាយព័ត៌មានពិតប្រាកដទេ នៅលើពិភពលោកនេះ។ សេរីភាពក្នុងការបញ្ចេញមតិដែលមាននៅក្នុងច្បាប់ តម្រូវឱ្យមានការអនុវត្តសេរីភាពនោះជាក់ស្តែង។ បើចង់ថែរក្សាឱ្យមានសេរីភាពក្នុងការបញ្ចេញមតិពិតប្រាកដនោះ អាជ្ញាធរ គឺត្រូវតែស៊ើបអង្កេតឱ្យបានត្រឹមត្រូវ នៅពេលណាមានការរំលោភកើតឡើង។

ដូចដែលរបាយការណ៍នេះបានបង្ហាញ ការបំភិតបំភ័យដោយក្រុមអ្នកមានអំណាច និងបក្សពួកអ្នកមានអំណាចនៅតែបន្តក្នុងរយៈពេល ១៥ខែ កន្លងទៅនេះ ដែលអង្គការលីកាដូបានពិនិត្យឡើងវិញ (ខែមករា ឆ្នាំ២០០៨ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩)។ ហើយករណីទាំងនោះ ដូចជាការវាយប្រហារ ឬការគំរាមកំហែងលើអ្នកសារព័ត៌មានដែលកំពុងតែអនុវត្តការងារនៅតែមិនមានការស៊ើបអង្កេតឱ្យច្បាស់លាស់ត្រឹមត្រូវនៅឡើយ។

ករណីដ៏គួរឱ្យរន្ធត់បំផុតនៅក្នុងរយៈពេលនៃការត្រួតពិនិត្យនេះ គឺឃាតកម្មលើអ្នកសារព័ត៌មានម្នាក់នៅភ្នំពេញឈ្មោះ ឃឹម សំបូរ។

ករណីឃាតកម្មបែបនេះ យ៉ាងតិចណាស់មានអ្នកសារព័ត៌មានចំនួន ១០នាក់ ដែលត្រូវបានគេសម្លាប់ចាប់តាំងពីរដ្ឋធម្មនុញ្ញនៃប្រទេសនេះត្រូវបានប្រកាសឱ្យប្រើប្រាស់នៅឆ្នាំ១៩៩៣។ ក្នុងករណីទាំងអស់នោះមិនឃើញមានឃាតករណាម្នាក់ត្រូវបានចាប់ខ្លួននាំទៅតុលាការទេ។ ធ្វើដូច្នេះ នាំឱ្យពួកអ្នកដែលប្រព្រឹត្តបទល្មើស ឬប្រើអំពើហិង្សាទៅលើអ្នកសារព័ត៌មាន និងបានទទួលនិទ្ទណ្ឌភាពពិតប្រាកដ (ធ្វើខុសច្បាប់អត់ជាប់ទោស)។

លោក ឃឹម សំបូរ ធ្វើការឱ្យសារព័ត៌មានមនសិការខ្មែរដែលមាននិន្នាការទៅគណបក្សជំទាស់ លោកត្រូវបានមនុស្សពីរនាក់ជិះទោចក្រយានមួយគ្រឿង បាញ់សម្លាប់នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ កន្លងទៅ។ កូនប្រុសរបស់លោកអាយុ ២១ ឆ្នាំ ឈ្មោះ ខាត់ សារិន ក៏ត្រូវបានគេបាញ់សម្លាប់នៅពេលនោះដែរ។ នគរបាលមិនបានរកឃើញអត្តសញ្ញាណជនល្មើស ឬពុំបានរកឃើញមូលហេតុនៃឃាតកម្មនោះទេ។

បើធ្វើតាមគន្លងករណីដែលកើតឡើងនៅអតីកាល នោះឃាតករ ដែលបាញ់សម្លាប់លោក ឃឹម សំបូរ មុខជាមិនត្រូវបានចាប់យកមកកាត់ទោសតាមច្បាប់ទេ។

លោក ឃឹម សំបូរ ធ្លាប់បានសរសេរអត្ថបទរិះគន់មន្ត្រីជាន់ខ្ពស់នៅក្នុងគណបក្សកាន់អំណាច។ ឃាតកម្មលើរូបលោកបានកើតឡើង ២ សប្តាហ៍មុនថ្ងៃបោះឆ្នោតជាតិ ឆ្នាំ២០០៨ តែប៉ុណ្ណោះ ហើយធ្វើឱ្យមានបរិយាកាសភ័យខ្លាចយ៉ាងខ្លាំង ក្នុងចំណោមអ្នកសារព័ត៌មាននានា។

ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាភាគច្រើន ច្រើនតែចងសម្ព័ន្ធភាពជាមួយគណបក្សនយោបាយណាមួយ ហើយភាគច្រើនលំអៀងគាំទ្រគណបក្សកាន់អំណាច។ ប៉ុន្តែ សម្ព័ន្ធភាពចម្រុះនេះអាចខុសគ្នា ទៅតាមប្រភេទប្រព័ន្ធផ្សាយព័ត៌មាន។ ឧទាហរណ៍ ស្ថានីយទូរទស្សន៍ទាំងអស់ សុទ្ធតែមានសម្ព័ន្ធភាពជាមួយគណបក្សប្រជាជនកម្ពុជា ឬជាមួយរដ្ឋាភិបាល (ដែលបញ្ហានេះដូចគ្នាទាំងអស់)។ ហើយចំណែកឯស្ថានីយវិទ្យុវិញ ភាគច្រើនក៏ដូចគ្នាដែរ។

ស្ថានភាពប្រព័ន្ធផ្សាយព័ត៌មានបោះពុម្ព មិនសូវរីតបណ្តឹងទេ ដូច្នេះហើយបានជាឃើញមានទស្សនៈផ្សេងៗ នៅក្នុងប្រព័ន្ធផ្សាយព័ត៌មានបែបនោះ។ ក៏ប៉ុន្តែ ដោយសារមានអត្រាអនក្ខរភាពទាបនៅក្នុងប្រទេសកម្ពុជា ផ្សំជាមួយបញ្ហាចែកចាយប្រព័ន្ធផ្សាយព័ត៌មានបោះពុម្ព និងការចំណាយច្រើនលើប្រព័ន្ធផ្សាយព័ត៌មានបោះពុម្ព ធ្វើឱ្យប្រជាពលរដ្ឋកម្ពុជា ចូលចិត្តរកព័ត៌មានតាមវិទ្យុ និងទូរទស្សន៍។ ដូច្នេះប្រព័ន្ធផ្សាយព័ត៌មាននោះ (វិទ្យុ និង ទូរទស្សន៍) ត្រូវបានត្រួតពិនិត្យយ៉ាងតឹងតែង។

ចំណុចដ៏ច្បាស់ល្អមួយ គឺជាការលេចចេញប្រព័ន្ធអ៊ីនធឺណិត ដែលជាវេទិកាសំរាប់ព័ត៌មាន និងទស្សនៈអំពីកម្ពុជា ជាភាសាខ្មែរ និងភាសាបរទេស។ អង្គការលីកាដូ បានរកឃើញគេហទំព័រ (វែបសាយ) ចំនួន១៨ ត្រូវបានកត់ត្រាចូលក្នុងបញ្ជីរបាយការណ៍នេះ។ ក៏ប៉ុន្តែ ឥទ្ធិពលរបស់គេហទំព័រនេះនៅមានកម្រិតទាបនៅឡើយ ដោយសារមានតែមនុស្សមួយចំនួនតូច ហើយភាគច្រើនជាអ្នកទីក្រុងប៉ុណ្ណោះដែលមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត។

មិនមែនមានតែអ្នកសារព័ត៌មានលោក ឃឹម សំបូរ មួយទេ ដែលត្រូវបានទទួលរងទុក្ខវេទនា។ មានអ្នកសារព័ត៌មានកម្ពុជាមួយទៀតដែលបម្រើការឱ្យវិទ្យុអាស៊ីសេរី ត្រូវបានភៀសខ្លួនចេញពីប្រទេសជាមួយគ្រួសារ ក្រោយពីបានទទួលការគំរាមកំហែងដល់អាយុជីវិតលោក។ ក្រោយមក លោកក៏បានទទួលសិទ្ធិជ្រកកោណនៅប្រទេស ន័រវេ។ អ្នកសារព័ត៌មានផ្សេងៗទៀត ក៏ត្រូវបានគេគំរាមគំហែងដែរ ឬមាន

សេចក្តីរាយការណ៍មកថា ត្រូវបានទទួលការរំខានធ្វើឱ្យកាន់តែមានការភិតភ័យខ្លាំងឡើង។ មានអ្នកសារព័ត៌មានម្នាក់ទៀត ត្រូវបានគេចាក់ដោយកាំបិតរហូតដល់បាត់បង់ជីវិត ហើយនគរបាលបានសន្និដ្ឋានថា គឺជាករណីប្លន់ខុសគោលដៅទៅវិញ។

មានប្រព័ន្ធផ្សាយព័ត៌មាន ដែលមានសម្ព័ន្ធភាពជាមួយគណបក្សជំទាស់ផ្សេងទៀត បានទទួលរងគ្រោះក្នុងរយៈពេលដែលអង្គការលីកាដូ ធ្វើរបាយការណ៍នេះ : មានស្ថានីយវិទ្យុខេត្តចំនួនពីរត្រូវបានបិទ ដែលអ្នកសារព័ត៌មានមួយចំនួនត្រូវបានទទួលការវាយប្រហារ ឬការគំរាមកំហែង (ច្រើនតែដោយមន្ត្រីប្រដាប់អាវុធរបស់រដ្ឋ)។ គ្មានរបាយការណ៍ណាមួយ ដែលគួរតែជឿទុកចិត្តបានរាយការណ៍អំពីការបំភិតបំភ័យលើប្រព័ន្ធផ្សាយព័ត៌មានដែលមានសម្ព័ន្ធភាពជាមួយគណបក្សកាន់អំណាចនៅកម្ពុជាឡើយ។

យ៉ាងតិចមានករណីបណ្តឹងពីរ ត្រូវបានប្តឹងអំពីបទបរិហារកេរ្តិ៍ក្រោមច្បាប់ព្រហ្មទណ្ឌអន្តរកាល[១] (គួរតែយកច្បាប់របបសារព័ត៌មានឆ្នាំ ១៩៩៥ ប្រើវិញ) ដែលករណីនេះ ត្រូវបានប្តឹងដោយទេសរដ្ឋមន្ត្រីម្នាក់នៅក្នុងគណបក្សកាន់អំណាច។ ច្បាប់របបសារព័ត៌មានបានចែងថា ពលរដ្ឋណាដែលមានអារម្មណ៍ថាត្រូវបានទទួលការបរិហារកេរ្តិ៍ដោយព័ត៌មាន នោះអាចស្វែងរកការដោះស្រាយតាមច្បាប់របបសារព័ត៌មានបាន (ដែលផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌ) តាមរយៈតុលាការ ការដោះស្រាយរួម មានការសរសេរកែតម្រូវឡើងវិញ ឬដោយការសងសំណងរដ្ឋប្បវេណី ពីសារព័ត៌មានដែលបានបរិហារកេរ្តិ៍គេនោះ។ បើប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌអន្តរកាល គឺជាទង្វើផ្ទុយទៅនឹងខ្លឹមសារច្បាប់របបសារព័ត៌មាននោះដែលបានចែងថា "គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌដោយសារតែការបញ្ចេញមតិឡើយ"។

ជាសង្ខេប បរិយាកាសប្រព័ន្ធផ្សាយព័ត៌មាននៅកម្ពុជា អាចល្អជាងប្រទេសមួយចំនួននៅក្នុងតំបន់ ហើយវាប្រាកដជាមានភាពល្អប្រសើរជាងមុនច្រើនណាស់ បើប្រៀបធៀបទៅនឹងសម័យប៉ុលពតដ៏ខ្មៅងងឹត និងក្រោយសម័យប៉ុលពតនោះ ប៉ុន្តែនៅមិនទាន់អាចហៅថា ជាប្រទេសមានសេរីភាពសារព័ត៌មានឡើយ។

នៅមានករណីជាច្រើនដែលគណបក្សកាន់អំណាច ជាអ្នកមានឥទ្ធិពលនៅក្នុងប្រព័ន្ធផ្សាយព័ត៌មានសម្លេង និងប្រព័ន្ធផ្សាយព័ត៌មានបោះពុម្ពនៅកម្ពុជា។ វត្តមាននៃសេរីភាពសារព័ត៌មាន ដែលត្រូវបានញាំញី

---

[១] ច្បាប់នេះត្រូវបានសេរសេរដោយ អង្គការសហប្រជាជាតិ ក្នុងសម័យអ៊ុនតាក់។ ច្បាប់នេះមានគោលបំណងត្រឹមតែជាច្បាប់ក្រមព្រហ្មទណ្ឌបណ្តោះអាសន្នតែប៉ុណ្ណោះ ប៉ុន្តែវានៅតែជាធរមាន។ ច្បាប់ព្រហ្មទណ្ឌថ្មី កំពុងត្រូវបានតាក់តែងឡើង ប៉ុន្តែពុំទាន់ចូលជាធរមាននៅឡើយទេ។

ដោយគំនាបនយោបាយ និងការបំភិតបំភ័យ។ សេរីភាពសារព័ត៌មាន គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យសេរី។ កម្ពុជា ក៏ដូចជាប្រទេសដទៃទៀតដែរ គឺអាចនឹងទទួលបាននូវសេរីភាពនេះ។ ដូចបានបង្ហាញនៅក្នុងរបាយការណ៍នេះ សេរីភាពប្រព័ន្ធផ្សាយព័ត៌មានកំពុងស្ថិតនៅយ៉ាងឆ្ងាយនៅឡើយ។

## វិធីសាស្ត្រ និងវិសាលភាពនៃរបាយការណ៍

របាយការណ៍នេះ គឺជារបាយការណ៍សរសេរបន្ថែមលើរបាយការណ៍របស់លីកាដូ ដែលបានចេញផ្សាយកាលពីខែឧសភា ឆ្នាំ២០០៨ ដែលមានចំណងជើងថា ***ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ: នយោបាយ ប្រាក់កាស និងការភ័យខ្លាច គ្រប់គ្រងប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា ដោយរបៀបណា***[២] ហើយមានគោលបំណងដើម្បីបង្ហាញអំពីការគាបសង្កត់ ដែលចេះតែបន្តឥតឈប់ឈរទៅលើប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា ដែលនៅមានរហូតមកដល់សព្វថ្ងៃនេះ។ របាយការណ៍នេះ បានផ្តល់នូវតារាងបញ្ជីបន្ថែមទៀតអំពីប្រព័ន្ធផ្សាយព័ត៌មានដូចជា: សារព័ត៌មាន វិទ្យុ ទូរទស្សន៍ និងអ៊ីនធឺណិត ហើយក៏មានតារាងបញ្ជាក់អំពីរបាយការណ៍ស្តីពីការវាយប្រហារ និងគំរាមកំហែងទៅលើប្រព័ន្ធផ្សាយព័ត៌មានក្នុងកំឡុងខែមករា ឆ្នាំ២០០៨ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ នេះ។

ព័ត៌មានទាំងឡាយដែលប្រើប្រាស់នៅក្នុងរបាយការណ៍នេះ គឺបានមកពីប្រភពបុគ្គលិកឃ្លាំមើលសិទ្ធិ មនុស្សលីកាដូ និងបុគ្គលិកផ្សេងទៀត (ធ្វើការនៅភ្នំពេញ និង១២ ខេត្តទៀត) និងដកស្រង់ចេញពីអត្ថបទសារព័ត៌មាននានាដូចជា ឌឺ ឃែមបូឌា ដេលី ភ្នំពេញប៉ុស្តិ៍ រស្មីកម្ពុជា កោះសន្តិភាព និងកម្ពុជាថ្មី។ ករណីទាំងឡាយដែលបង្ហាញឱ្យឃើញយ៉ាងច្បាស់នូវការគាបសង្កត់លើសេរីភាពក្នុងការបញ្ចេញមតិ គឺត្រូវបានជ្រើសរើសធ្វើជាករណីសិក្សា។

របាយការណ៍នេះ ពុំបានអះអាងថាជារបាយការណ៍ទូទៅ ដែលឆ្លុះបញ្ចាំងនូវស្ថានភាព សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជាក្នុងកំឡុងពេលនោះឡើយ ដោយធនធានមានកំណត់ និងករណីជាច្រើនដែលពុំដឹងមូលហេតុច្បាស់លាស់ និងពិបាករកព័ត៌មាន ធ្វើឱ្យករណីទាំងនោះ មិនអាចលើកយកមកនិយាយបាន។ ប៉ុន្តែរបាយការណ៍នេះមានគោលបំណងត្រឹមតែរក្សាទុកជាឯកសារ នូវករណីច្បាស់លាស់មួយចំនួន អំពីការដាក់កម្រិតលើសេរីភាពក្នុងការបញ្ចេញមតិ នៅក្នុងប្រព័ន្ធផ្សាយព័ត៌មាននៅកម្ពុជា និងដើម្បីផ្តល់នូវទស្សនៈនៃបរិយាកាសនៃការប្រតិបត្តិការប្រព័ន្ធផ្សាយសារព័ត៌មានតែប៉ុណ្ណោះ។

□□□

---

[២] http://licadho-cambodia.org/reports.php?perm=119

# ២. ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកម្ពុជា

## ស្ថានីយទូរទស្សន៍

ស្ថានីយទូរទស្សន៍នៅកម្ពុជាទាំង ៨ សុទ្ធតែមានសម្ព័ន្ធភាពជាមួយគណបក្សកាន់អំណាច ហើយព្រឹត្តិបត្រសារព័ត៌មានទាំងឡាយសុទ្ធតែមានលក្ខណៈលំអៀងផ្នែកនយោបាយ។ សេចក្តីរាយការណ៍ព័ត៌មាននានា ច្រើនតែរៀបរាប់អំពីសកម្មភាពរបស់មន្ត្រីរដ្ឋាភិបាល ឬ ក្រុមមន្ត្រីរាជការណាមួយ (ភាគច្រើនជាសមាជិកគណបក្សកាន់អំណាច) ធ្វើដំណើរទៅតំបន់ជនបទ ដើម្បីពិនិត្យមើលការដ្ឋាន កសាងផ្លូវ ឬ ស្ពាន ឬ ចែកអំណោយជូនប្រជាពលរដ្ឋនៅតាមភូមិ ឃុំនានា។

សុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី តែងតែត្រូវបានចាក់ផ្សាយឡើងវិញ នៅគ្រប់ស្ថានីយទូរទស្សន៍ទាំងអស់ លើកលែងតែស្ថានីយមួយឈ្មោះ ម៉ាយ ធី វី តែប៉ុណ្ណោះ ដែលជាទូរទស្សន៍មិនផ្សាយព័ត៌មាន ហើយផ្តោតតែទៅលើកម្មវិធីកម្សាន្តសម្រាប់យុវវ័យប៉ុណ្ណោះ។ ស៊ី ធី អិន គឺជាស្ថានីយទូរទស្សន៍ដែលមានប្រជាប្រិយភាពជាងគេ។ ស្ថានីយនេះផ្សាយព័ត៌មានផ្សេងៗជាច្រើន និងកម្មវិធីព័ត៌មាន ដូចជាការផ្សាយបន្តផ្ទាល់អំពីព្រឹត្តិការណ៍នានាជាដើម។

បណ្តាញទូរទស្សន៍កម្ពុជា ស៊ី ធី អិន បានធ្វើការផ្សាយព័ត៌មានក្នុងស្រុក ជាលក្ខណៈអន្តរជាតិទៅប្រទេសជាច្រើនដូចជា: អូស្ត្រាលី កាណាដា អាមេរិក និង ញូហ្សេឡេន ជាដើម។ ស្ថានីយទូរទស្សន៍អប្សរា បាយ័ន និងទូរទស្សន៍ជាតិកម្ពុជា ក៏ផ្សាយជាលក្ខណៈអន្តរជាតិដែរ តាមរយៈផ្កាយរណប។

| ល.រ | ស្ថានីយ | ម្ចាស់កម្មសិទ្ធិ/អ្នកគ្រប់គ្រង | ព័ត៌មានបន្ថែម |
|---|---|---|---|
| ១ | ទូរទស្សន៍អប្សរា | ▪ តាមផ្លូវការជារបស់ក្រុមហ៊ុនសារព័ត៌មានអប្សរា ទោះបីជា នាយកក្រុមហ៊ុននេះមិនចេញមុខថាជានរណាក៏ដោយ ក៏ត្រូវគេរាយការណ៍ថា ជារបស់គណបក្សប្រជាជនកម្ពុជា។<br>▪ អគ្គនាយកឈ្មោះ លោក សុខ ឮសាន្ត | ▪ ក្នុងឆ្នាំ២០០៦ ស្ថានីយនេះបានចាប់ដៃគូជាមួយក្រុមហ៊ុនបារាំងឈ្មោះសូឡារីអន្តរជាតិដើម្បីកែលំអរបច្ចេកវិទ្យា មាតិកាកម្មវិធី និងកម្លាំងផ្សាយ។<br>▪ ស្ថានីយទូទស្សន៍អប្សរានេះក៏មាន |

| | | | |
|---|---|---|---|
| | | ជាសមាជិកគណកម្មាធិការកណ្តាល ដែលមានតួនាទីទទួល "ភារកិច្ចចំពោះប្រជាពលរដ្ឋ" ។ | ស្ថានីយវិទ្យុមួយផងដែរ ។<br>▪ **ការផ្សាយ:** ស្ថានីយទូរទស្សន៍អប្សរាផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិ បញ្ចាំងខ្សែភាពយន្តឥណ្ឌា ឥណ្ឌូនេស៊ី ការពិភាក្សានយោបាយ និងកម្មវិធីកម្សាន្តផ្សេងទៀត ។ |
| ២ | ទូរទស្សន៍ បាយ័ន | ▪ ត្រូវបានគេដឹងជាទូទៅថា ជារបស់គ្រួសារនាយករដ្ឋមន្ត្រី<br>▪ បច្ចុប្បន្ននេះគ្រប់គ្រង ដោយកូនស្រីសម្តេចនាយករដ្ឋមន្ត្រីឈ្មោះ ហ៊ុន ម៉ាណា ដែលកាលពីខែកញ្ញា ឆ្នាំ២០០៨ ត្រូវបានតែងតាំងជាជំនួយការនាយករដ្ឋមន្ត្រី ។ | ▪ បានបង្កើតឡើងនៅឆ្នាំ១៩៩៨<br>▪ អស់រយៈពេលជាច្រើនឆ្នាំ អង់តែនទូរទស្សន៍បាយ័នស្ថិតនៅក្នុងរង្វង់ទីតាំងការពាររបស់សម្តេចនាយករដ្ឋមន្ត្រី នៅជាយក្រុងភ្នំពេញ ។<br>▪ សម្តេចនាយករដ្ឋមន្ត្រី និងភរិយា បានកាត់ខ្សែបូរណិ សម្ពោធទីតាំងថ្មីរបស់ស្ថានីយទូរទស្សន៍បាយ័ន កាលពីខែមីនា ឆ្នាំ២០០៧ កន្លងទៅនេះ ។<br>▪ ដូចទូរទស្សន៍អប្សរាដែរ ទូទស្សន៍បាយ័នក៏មានស្ថានីយវិទ្យុមួយដែរ ។<br>▪ **ការផ្សាយ:** បញ្ចាំងខ្សែភាពយន្តខ្មែរ កូរ៉េ ចិន និងអាមេរិកកាំង កម្មវិធីអប់រំ តន្ត្រី កម្មវិធីវិភាគព័ត៌មានកីឡាប្រដាល់ កំប្លែង និងសកម្មភាពរបស់គណបក្សប្រជាជនកម្ពុជា ។ |
| ៣ | បណ្តាញស្ថានីយទូរទស្សន៍កម្ពុជា ( ស៊ី ធី អិន ) | ▪ ជារបស់ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប គ្រប់គ្រងដោយមហាសេដ្ឋីខ្មែរ-អូស្ត្រាលី លោក គិត | ▪ បណ្តាញទូរទស្សន៍កម្ពុជា (ស៊ី ធី អិន) ជាស្ថានីយថ្មី និងទំនើបជាងគេ |

| | | | |
|---|---|---|---|
| | | ម៉េង បច្ចុប្បន្នជាប្រធានសភាពាណិជ្ជកម្មជាតិ។ លោកជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីដែលគេស្គាល់ថា ជាមនុស្សជិតស្និទ្ធជាមួយរដ្ឋាភិបាល។ | បង្អស់ក្នុងចំណោមស្ថានីយទាំងឡាយ<br>▪ ក្នុងខែមីនា ឆ្នាំ២០០៣ ស្ថានីយទូរទស្សន៍នេះ បានចាប់ដៃគ្នារវាងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប និងក្រុមហ៊ុន Stockholm-based Modern Time Group<br>▪ **ការផ្សាយ:** ផ្សាយព័ត៌មានពេលព្រឹក ព័ត៌មានជាតិ និងអន្តរជាតិ ការប្រគំតន្ត្រី កំប្លែង កម្មវិធីទូរទស្សន៍បរទេស កីឡា កម្មវិធីអប់រំ ខ្សែភាពយន្តខ្មែរ និងកូរ៉េ និងកម្មវិធីកម្សាន្តផ្សេងៗទៀត។ |
| | ស៊ី ធី អិន អន្តរជាតិ | ▪ ជារបស់ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប គ្រប់គ្រងដោយមហាសេដ្ឋីខ្មែរ-អូស្ត្រាលី លោក គិត ម៉េង | ▪ ផ្សាយព័ត៌មានខ្មែរនៅក្នុងប្រទេស និងកម្មវិធីអន្តរជាតិដទៃទៀត។<br>▪ កម្មវិធីនេះស្របគ្នាជាមួយស៊ីធីអិន។ |
| ៤ | ម៉ាយ ធី វី | ▪ ជារបស់ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប គ្រប់គ្រងដោយមហាសេដ្ឋីខ្មែរ-អូស្ត្រាលី លោក គិត ម៉េង | ▪ ជាផ្នែកមួយរបស់ ស៊ី ធី អិន និង ម៉ូប៊ីថែល<br>▪ ជាស្ថានីយថ្មី គ្រប់កម្មវិធីទាំងអស់បង្កើតឡើងដើម្បីទាក់ទាញយុវវ័យ<br>▪ **ការផ្សាយ:** កម្មវិធីកម្សាន្ត ចំម្រៀងជាតិ និងអន្តរជាតិ និងកម្មវិធីអប់រំ។ |
| ៥ | ទូរទស្សន៍រាជធានីភ្នំពេញ ប៉ុស្តិ៍លេខ ៣ | ▪ ម្ចាស់ភាគហ៊ុន គឺមន្ទីរព័ត៌មានរាជធានីភ្នំពេញ និងក្រុមហ៊ុនថៃឈ្មោះ KCS Cambodia ។<br>▪ អគ្គនាយកទូរទស្សន៍ប៉ុស្តិ៍លេខ៣ឈ្មោះ លោក ខាំពូន កែវមុន្នី គឺជាទីប្រឹក្សា | ▪ **ការផ្សាយ:** កម្មវិធីព័ត៌មានពេលព្រឹក ខ្សែភាពយន្តខ្មែរ កូរ៉េ និងអាមេរិក-កាំង កម្មវិធីកំប្លែង ព័ត៌មានជាតិ និងអន្តរជាតិ ចំរៀង និងការផ្សាយផ្ទាល់ការប្រគំតន្ត្រី។ |

| | | | |
|---|---|---|---|
| | | សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និង បច្ចុប្បន្នប្រធានគណបក្សប្រជាជនកម្ពុជា។ | |
| ៦ | ទូរទស្សន៍កងយោធពលខេមរភូមិន្ទប៉ុស្ដិ៍លេខ ៥ | ▪ ក្រសួងការពារជាតិមានភាគហ៊ុនមួយភាគ និងប្រព័ន្ធផ្សាយព័ត៌មាន MICA មានភាគហ៊ុនមួយភាគ។<br>▪ អគ្គនាយកស្ថានីយឈ្មោះ ខែម គុណវឌ្ឍន៍ សមាជិកគណៈកម្មាធិការកណ្ដាលនៃគណបក្សប្រជាជនកម្ពុជា។ | ▪ **ការផ្សាយ:** កម្មវិធីព័ត៌មានជាតិ និងអន្តរជាតិ ខ្សែភាពយន្តខ្មែរ កូរ៉េ និងប្រទេសសេរី កម្មវិធីអប់រំ និងកម្មវិធីកម្សាន្តផ្សេងទៀត។ |
| ៧ | ទូរទស្សន៍ខ្មែរប៉ុស្ដិ៍លេខ ៩ | ▪ ត្រូវគេអះអាងថា "បានទទួលអាជ្ញាប័ណ្ណជាក្រុមហ៊ុនឯកជន ១០០%"។<br>▪ គេជឿជាក់ថាស្ថានីយនេះជារបស់គ្រួសារលោក ឃុន ហាំង ដែលជាអតីតរដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា (ហ៊្វុនស៊ីនប៉ិច) ហើយគ្រប់គ្រងដោយសាច់ញាតិគ្រួសាររបស់លោក ដែលបានចុះចូលគណបក្សប្រជាជនកម្ពុជាមុនការបោះឆ្នោតជាតិ ឆ្នាំ២០០៨។ | ▪ ស្ថាបនាឡើង ដោយគណបក្ស ហ៊្វុនស៊ីនប៉ិចកាលពីដើមទស្សវត្ស ១៩៩០<br>▪ រហូតមកដល់ ១៩៩៧ វាជាស្ថានីយដែលផ្សាយពីបញ្ហាមិនជំទាស់ខាងវិស័យនយោបាយ ដោយគាំទ្រគណបក្សហ៊្វុនស៊ីនប៉ិច និងរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជាជនកម្ពុជា។ ព្រឹត្តិការណ៍ឆ្នាំ១៩៩៧ ស្ថានីយទូរទស្សន៍នេះផ្សព្វផ្សាយឱ្យគណបក្សហ៊្វុនស៊ីនប៉ិច ហើយតែងតែជំទាស់នឹងគណបក្សប្រជាជនកម្ពុជា។ ទូរទស្សន៍ខ្មែរប៉ុស្ដិ៍លេខ ៩ (ជាមួយស្ថានីយវិទ្យុរបស់គណបក្សហ៊្វុនស៊ីនប៉ិច) ត្រូវបានវាយប្រហារក្នុងព្រឹត្តិការណ៍នេះ ក្រោយមកត្រូវបានគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា។<br>▪ ក្រោយមកទើបប្រគល់ជូនវិញ ហើយ |

| | | | |
|---|---|---|---|
| | | | បច្ចុប្បន្នស្ថានីយវិទ្យុនេះ ស្ថិតនៅក្នុងដៃលោកឃុន ហាំង។<br>▪ **ការផ្សាយ:** ខ្សែភាពយន្តខ្មែរ អាមេរិកកាំង និងចិន ព័ត៌មានជាតិ និងអន្តរជាតិ កម្មវិធីអប់រំ និងកម្មវិធីកម្សាន្តផ្សេងទៀត។ |
| ៨ | ទូរទស្សន៍ជាតិកម្ពុជា **ទទក** | ▪ ត្រូវបានគ្រប់គ្រងដោយក្រសួងព័ត៌មាន ។ | ▪ មានការត្រួតពិនិត្យយ៉ាងតឹងរឹងមុននឹងចេញផ្សាយបញ្ហាស្មុកស្មាញ។<br>▪ **ការផ្សាយ:** ព័ត៌មានជាតិ និងអន្តរជាតិ បញ្ចាំងខ្សែភាពយន្តខ្មែរ ចិន កម្មវិធីអប់រំ និងកម្មវិធីកម្សាន្តនានា។ |

គ្រប់ស្ថានីយទូរទស្សន៍ទាំងអស់សុទ្ធតែផ្សាយបានតាមសេរី ប៉ុន្តែមិនអាចផ្សាយទៅគ្រប់តំបន់ក្នុងប្រទេសទេ ដូច្នេះនៅក្នុងខេត្តមួយចំនួន ត្រូវមានស្ថានីយទូរទស្សន៍ខ្សែកាប ដើម្បីអាចទស្សនាការផ្សាយរបស់ស្ថានីយផ្សេងៗទៀតបាន ។

**ស្ថានីយទូរទស្សន៍ដែលមានស្ថានីយផ្សាយបន្ត មានដូចជា :**

- ទូរទស្សន៍បាយ័ន (មាននៅខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តស្ទឹងត្រែង)
- បណ្តាញស្ថានីយទូរទស្សន៍កម្ពុជា ស៊ី ធី អិន (មាននៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តព្រះសីហនុ ខេត្តសៀមរាប និង ខេត្តស្វាយរៀង)
- ទូរទស្សន៍កងយោធពលខេមរភូមិន្ទ ប៉ុស្តិ៍លេខ ៥ (មាននៅខេត្តក្រចេះ ខេត្តព្រះសីហនុ និងខេត្តសៀមរាប)
- ទូរទស្សន៍រាជធានីភ្នំពេញ ប៉ុស្តិ៍លេខ ៣ (មាននៅខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តព្រះសីហនុ និងខេត្តសៀមរាប)

- ទូរទស្សន៍ជាតិកម្ពុជា ទទក (មាននៅខេត្តបាត់ដំបង ខេត្តកោះកុង ខេត្តមណ្ឌលគីរី ខេត្តពោធិ៍សាត់ ខេត្តរតនគីរី ខេត្តសៀមរាប និងខេត្តព្រះសីហនុ)
- ទូរទស្សន៍ខ្មែរប៉ុស្តិ៍លេខ ៩ (មាននៅខេត្តបាត់ដំបង និងខេត្តសៀមរាប)

## ស្ថានីយវិទ្យុ

### ភ្នំពេញ

ស្ថានីយវិទ្យុភាគច្រើន ដែលមានទីតាំងនៅភ្នំពេញ សុទ្ធតែមានសម្ព័ន្ធភាពជាមួយគណបក្សកាន់អំណាច អាស្រ័យដោយស្ថានីយទាំងនោះជារបស់ ឬគាំទ្រដោយអ្នកមានអំណាច ដោយបក្សពួក និង/ឬ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគណបក្សកាន់អំណាច។ ខ្លឹមសារផ្សាយចេញពីស្ថានីយទាំងនោះ គឺគាំទ្ររដ្ឋាភិបាល និងលំអៀងទៅខាងគណបក្សប្រជាជនកម្ពុជាយ៉ាងខ្លាំង ដោយច្រើនតែផ្សាយអំពីសមិទ្ធផលរបស់រាជរដ្ឋាភិបាល និងសកម្មភាពវិជ្ជមាននានា របស់គណបក្សប្រជាជនកម្ពុជា និងឥស្សរជន គាំទ្រនានា (ដោយពុំមានការជំទាស់ និងផ្សាយរិះគន់ឡើយ)។ ព័ត៌មានអវិជ្ជមានអំពីរដ្ឋាភិបាល ឬ ទស្សនៈជំទាស់ គឺមិនផ្សាយទេ។ គេជឿជាក់ថា វិទ្យុបាយ័ន គឺជាស្ថានីយកាន់កាប់ដោយកូនស្រីរបស់ សម្តេចនាយករដ្ឋមន្ត្រី ឈ្មោះ ហ៊ុន ម៉ាណា ដែលផ្សាយព័ត៌មានពេលព្រឹករិះគន់គណបក្សជំទាស់ដោយចំហរ។

មានស្ថានីយវិទ្យុពីរជាស្ថានីយអព្យាក្រិត្យៈ គឺវិទ្យុសម្បុកឃ្មុំ និងមណ្ឌលព័ត៌មានស្ត្រីកម្ពុជា FM ១០២។ ស្ថានីយវិទ្យុ FM ១០២ នេះជារបស់អង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមានឈ្មោះដូចវិទ្យុនេះដែរ ហើយច្រើនតែផ្សាយអំពីបញ្ហាសិទ្ធិស្ត្រី ជាធម្មតាមិនផ្សាយទស្សនៈណា ដែលរិះគន់រដ្ឋាភិបាលឡើយ។ ប៉ុន្តែ វិទ្យុសម្បុកឃ្មុំ មិនខ្លាចនឹងផ្សាយរិះគន់ឡើយ ហើយសាធារណជនទូទៅចាត់ទុកថាជាស្ថានីយវិទ្យុដែលមានឯករាជ្យជាងគេ។ ស្ថានីយនេះច្រើនតែផ្សាយរិះគន់រដ្ឋាភិបាល។

ស្ថានីយវិទ្យុដែលគាំទ្រគណបក្សជំទាស់មានដូចជា : វិទ្យុសុវណ្ណភូមិ និង FM ៩៣.៥ ដែលគាំទ្រគណបក្សសម រង្ស៊ី វិទ្យុតាព្រហ្ម និង FM ៩០ គាំទ្រគណបក្សហ៊្វុនស៊ីនប៉ិច ដែលជាដៃគូរដ្ឋាភិបាលចម្រុះរបស់គណបក្សប្រជាជនកម្ពុជា។

ស្ថានីយវិទ្យុសម្បុកឃ្មុំ វិទ្យុសុវណ្ណភូមិ វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា និងវិទ្យុ FM ៩៣.៥ គឺជាស្ថានីយវិទ្យុ ដែលមានសេចក្តីក្លាហានហ៊ានជួលម៉ោងផ្សាយឱ្យទៅវិទ្យុអាស៊ីសេរី និងវិទ្យុសម្លេងសហរដ្ឋ

អាមេរិកដែលទទួលមូលនិធិពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ព្រមទាំងជួលម៉ោងផ្សាយឱ្យស្ថានីយវិទ្យុ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដូចជា៖ វិទ្យុសម្លេងប្រជាធិបតេយ្យ និងក្រុមសិទ្ធិមនុស្សនានា ដែលផ្សាយព័ត៌មានឯករាជ្យ និងច្រើនតែរិះគន់រដ្ឋាភិបាល។

| ល.រ | ឈ្មោះ | រលកធាតុអាកាស (MHz) | ម្ចាស់/ ប្រធានគ្រប់គ្រង និង សម្ព័ន្ធភាពផ្នែកនយោបាយ | ព័ត៌មានបន្ថែម |
|---|---|---|---|---|
| **ស្ថានីយវិទ្យុ AM** | | | | |
| ១ | ជាតិកម្ពុជា | AM៩១៨ MHz | • វិទ្យុជាតិគ្រប់គ្រងដោយរដ្ឋ<br>• គណបក្សប្រជាជនកម្ពុជា | **ភាសា៖**ព័ត៌មានភាសាខ្មែរ និងភាសា អង់គ្លេស<br>**ការផ្សាយ៖** ព័ត៌មាន<br>**ទីតាំង៖** អាគារលេខ ៦ កែងផ្លូវ ១៩ និង ១០២ ខ័ណ្ឌដូនពេញ ភ្នំពេញ<br>ទូរស័ព្ទ៖ (៨៥៥)២៣ ៧២២ ៨៦៩<br>ទូរសារ៖(៨៥៥)២៣ ៤២៧ ៣១៩ |
| **ស្ថានីយវិទ្យុ FM** | | | | |
| ២ | Sweet FM | FM៨៨.0 MHz | • លោក អ៊ឹង សេដ្ឋាមូលី (សាច់ញាតិ អតីតរដ្ឋមន្ត្រីក្រសួងព័ត៌មាន អៀង មូលី) ឬក៏ជានាយករដ្ឋមន្ត្រី<br>• គណបក្សប្រជាជនកម្ពុជា | **ភាសា៖** ភាសាខ្មែរ និងចិន<br>**ការផ្សាយ៖** កម្មវិធីតន្ត្រី និងអប់រំ<br>**ទីតាំង៖** ផ្ទះលេខ ២ មហាវិថីសហព័ន្ធរុស្ស៊ី ភ្នំពេញ<br>ទូរស័ព្ទ៖ (៨៥៥)២៣ ៩៨២ ២៦៥<br>(៨៥៥)១២ ៨០៥ ៤៥៩<br>ទូរសារ៖(៨៥៥)២៣ ៣៦០ ៨០០ |
| ៣ | FM ៩០ | FM៩0.0 MHz | • ហ៊ុនស៊ីនប៉ិច | **ភាសា៖** ភាសារខ្មែរ<br>**ការផ្សាយ៖** ព័ត៌មាន កម្មវិធីតន្ត្រី និងអប់រំ |

| | | | | |
|---|---|---|---|---|
| | | | | **ទីតាំង:** ចំការដូង ភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥)១៦ ៧០៩ ០៩០ |
| ៤ | តាព្រហ្ម | FM៩០.៥ MHz | • ពីមុនពួថាចេញអាជ្ញាប័ណ្ណឱ្យសមាជិកសភាគណបក្សហ៊្វុនស៊ិនប៊ិច លោក អៀម លឹមសួរ<br>• គណបក្សហ៊្វុនស៊ិនប៊ិច | **ភាសា:** ព័ត៌មានភាសាខ្មែរ និង អង់គ្លេស<br>**ការផ្សាយ:** ព័ត៌មាន និងកម្មវិធីកម្សាន្តនានា<br>**ទីតាំង:** ផ្ទះលេខ ២៧បេ ផ្លូវ៤៧២ ភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥)២៣ ៩៩៣ ២០៦ |
| ៥ | FM ៩៣.៥ | FM៩៣.៥ MHz | • អតីតសម្ព័ន្ធភាពគណបក្សប្រជាធិប-តេយ្យសេរីនិយមព្រះពុទ្ធសាសនា ដែលម្ចាស់បច្ចុប្បន្នមិនច្បាស់លាស់។<br>• គេជឿថាមានទំនោរទៅខាងគណបក្សសម រង្ស៊ី | ស្ថានីយវិទ្យុមួយក្នុងចំណោមស្ថានីយទាំងឡាយ ដែលបានជួលម៉ោងផ្សាយទៅឱ្យវិទ្យុអាស៊ីសេរី វិទ្យុសំលេងសហរដ្ឋអាមេរិក និង សំលេងប្រជាធិបតេយ្យ<br>**ភាសា:** ខ្មែរ<br>**ការផ្សាយ:** ព័ត៌មាន និងកម្មវិធីកម្សាន្ត<br>**ទីតាំង:** ផ្ទះលេខ ២៩E0 ផ្លូវ២១០ ភ្នំពេញ<br>ទូរស័ព្ទ:(៨៥៥)២៣ ៣៥៩ ៣៥០ |
| ៦ | បាយ័ន FM | FM៩៥.0 MHz | • តាមរបាយការណ៍បានឱ្យដឹងថា (នៅជាមួយនឹងទូរទស្សន៍បាយ័ន)ហើយម្ចាស់គឺគ្រួសាររបស់សម្តេចនាយករដ្ឋមន្ត្រី។<br>• អគ្គនាយក គឺកូនស្រីរបស់សម្តេចនាយករដ្ឋមន្ត្រី ឈ្មោះ ហ៊ុន ម៉ាណា | **ភាសា:** ខ្មែរ<br>**ការផ្សាយ:** វិភាគព័ត៌មាន តន្ត្រី និងកម្មវិធីកម្សាន្ត នានា<br>**ទីតាំង:** ផ្ទះលេខ២២ ផ្លូវ១០៦ ទួលក្រសាំង ខេត្តកណ្តាល<br>ទូរស័ព្ទ: (៨៥៥)២៣ ៨៨០ ៨៧៤ |

| | | | | |
|---|---|---|---|---|
| | | | • គណបក្សប្រជាជនកម្ពុជា | ទូរសារ: (៨៥៥)២៣ ៩៨៣ ៨៩៥ |
| ៧ | វិទ្យុជាតិកម្ពុជា FM | FM៩៦.0 MHz | • វិទ្យុជាតិគ្រប់គ្រងដោយរដ្ឋ<br>• គណបក្សប្រជាជនកម្ពុជា | **ភាសា:** ព័ត៌មានភាសាខ្មែរ និង អង់គ្លេស<br>**ការផ្សាយ:** ព័ត៌មាន និងកម្មវិធីកម្សាន្ត<br>**ទីតាំង:** ចំការដូង ភ្នំពេញ |
| ៨ | មិត្តភាពកម្ពុជា ចិន | FM៩៦.៥ MHz | • វិទ្យុជាតិកម្ពុជាសហការជាមួយនឹងវិទ្យុចិនហៅថា វិទ្យុចិនអន្តរជាតិ ។<br>• គណបក្សប្រជាជនកម្ពុជា ។ | **ភាសា :** ភាសាខ្មែរ និងចិន<br>**ការផ្សាយ:** ព័ត៌មានស្តីពីប្រទេសចិន និងពិភពលោក តន្ត្រីចិន និងខ្មែរ |
| ៩ | អប្សរា FM | FM៩៧.0 MHz | • មិនប្រាប់ឈ្មោះម្ចាស់ ប៉ុន្តែជាទូទៅគេជឿថាជារបស់គណបក្សប្រជាជនកម្ពុជា គ្រប់គ្រងដោយលោក សុខ ឥសាន សមាជិកគណកម្មាធិការកណ្តាល នៃគណបក្សប្រជាជនកម្ពុជា<br>• គណបក្សប្រជាជនកម្ពុជា | **ភាសា:** ភាសាខ្មែរ<br>**ការផ្សាយ:** ព័ត៌មាន កម្មវិធី អប់រំ និងកម្សាន្ត<br>**ទីតាំង:** នៅស្ថានីយទូរទស្សន៍ (អប្សរាប៉ុស្តិ៍លេខ ១១) ផ្ទះលេខ៦៩ ផ្លូវលេខ៥៧ (កាច់ជ្រុងផ្លូវ ៣៧០) ភ្នំពេញ<br>ទូរស័ព្ទ និងទូរសារ: (៨៥៥) ២៣ ៣១៤ ៣០២ |
| ១០ | FM សេចក្តីស្រឡាញ់ | FM៩៧.៥ MHz | • ម្ចាស់ពីរ គឺសាលារាជធានីភ្នំពេញ និង ក្រុមហ៊ុន KSC Cambodia ។<br>• មិនបម្រើនយោបាយ (មិនពិភាក្សាវែកញែកពីបញ្ហានយោបាយទេ) ។ | **ភាសា:** ភាគច្រើនភាសាអង់គ្លេស ភាសាខ្មែរខ្លះៗ<br>**ការផ្សាយ:** ស្ថានីយតន្ត្រីតាមបែបប្រជាប្រិយ ។ ផ្សាយព័ត៌មានជាភាសាអង់គ្លេសបន្តពីវិទ្យុអូស្ត្រាលី ។<br>**ទីតាំង:** នៅស្ថានីយទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ ៣ ផ្ទះលេខ២ |

| | | | | |
|---|---|---|---|---|
| | | | | មហាវិថីសហព័ន្ធរុស្សី ភ្នំពេញ |
| ១១ | កងយោធពលខេមរភូមិន្ទ FM | FM៩៨.0 MHz | • មានម្ចាស់ជាមួយស្ថានីយទូរទស្សន៍កងយោធពលខេមរភូមិន្ទប៉ុស្តិ៍លេខ ៥ និងមានការសហការរវាងក្រសួងការពារជាតិ និងក្រុមហ៊ុន MICA Media Co.Ltd ។<br>• គណបក្សប្រជាជនកម្ពុជា | **ភាសា**: ខ្មែរ<br>**ការផ្សាយ**: ភាគច្រើន កម្មវិធីកម្សាន្ត<br>**ទីតាំង:** នៅស្ថានីយទូរទស្សន៍កងយោធពលខេមរភូមិន្ទប៉ុស្តិ៍លេខ ៥ ផ្លូវ ១៦៤ ភ្នំពេញ<br>ទូរស័ព្ទ:(៨៥៥)២៣ ៣០៣ ៩២៥ |
| ១២ | FM ៩៩ | FM៩៩.0 MHz | • អគ្គនាយក គឺលោក គីម ហឿន<br>• គណបក្សប្រជាជនកម្ពុជា | **ភាសា**: ខ្មែរ<br>**ការផ្សាយ**: ព័ត៌មាន តន្ត្រី និងកម្មវិធីកម្សាន្ត<br>**ទីតាំង:** នៅស្ថានីយទូរទស្សន៍អប្សរា (ប៉ុស្តិ៍លេខ ១១) ផ្ទះលេខ ៦៩ ផ្លូវលេខ ៥៧ (កាច់ជ្រុងផ្លូវ ៣៧០) ភ្នំពេញ<br>ទូរស័ព្ទ:(៨៥៥)២៣ ២១២ ៣៧៦ |
| ១៣ | គ្រួសារ FM (ស្ថានីយវិទ្យុគ្រិស្តសាសនា) | FM៩៩.៥ MHz | • ក្រុមហ៊ុនផ្សព្វផ្សាយចុងបូព៌ាកម្ពុជា<br>• មិនបម្រើនយោបាយ | **ភាសា:** ខ្មែរ<br>**ការផ្សាយ:**ភាគច្រើនផ្សព្វផ្សាយកម្មវិធីសិក្សាអំពីព្រះយេស៊ូគ្រិស្ត<br>**ទីតាំង:** ផ្ទះលេខ៨បេ ផ្លូវ៣៩៥ ភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥)២៣ ៩៨២ ១៩៩<br>ទូរសារ: (៨៥៥)២៣ ៩៨២ ០៤៥ |
| ១៤ | វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា | FM១០២ MHz | • ម្ចាស់ និងគ្រប់គ្រងដោយអង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា<br>• អព្យាក្រិត្យ | **ភាសា:** ភាសាខ្មែរ និងអង់គ្លេសខ្លះ<br>**ទីតាំង:** មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ផ្ទះលេខ៣០ ផ្លូវ៤៨៨ សង្កាត់ផ្សារ |

| | | | | |
|---|---|---|---|---|
| | | | | ដើមថ្កូវ ខណ្ឌចំការមន ភ្នំពេញ<br>ទូរស័ព្ទ:(៨៥៥)២៣ ២១២ ២៦៤<br>ទូរសារ:(៨៥៥)២៣ ៣៦៤ ៨៨២ |
| **១៥** | រាជធានីភ្នំពេញ | FM១០៣ MHz | • ម្ចាស់ពីរ គឺមន្ទីរព័ត៌មាននៃសាលារាជធានីភ្នំពេញ និងក្រុមហ៊ុន KSC Cambodia ។<br>• គណបក្សប្រជាជនកម្ពុជា | **ភាសា:** ខ្មែរ អង់គ្លេស និងឥស្លាម<br>**ទីតាំង:** នៅស្ថានីយទូរទស្សន៍ រាជធានីភ្នំពេញ (ប៉ុស្តិ៍លេខ ៣) ផ្ទះលេខ ២ ផ្លូវសហព័ន្ធរុស្ស៊ី (ផ្លូវ ១១២) ភ្នំពេញ |
| **១៦** | សុវណ្ណភូមិ FM | FM 104 MHz | • មិនស្គាល់<br>• គណបក្សសមរង្ស៊ី | **ភាសា:** ខ្មែរ<br>**ការផ្សាយ:** ព័ត៌មាន កម្មវិធីកម្សាន្ត និងតន្ត្រី<br>**ទីតាំង:** ជើងឯក សង្កាត់ជើងឯក ខណ្ឌមានជ័យ ភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥)១១ ៤៤៤ ១០៤<br>ឬ (៨៥៥)១២ ៧៨៧ ៥០៥ |
| **១៧** | ហង្សមាស | FM១០៤.៥ MHz | • ក្រុមហ៊ុនឧស្សាហកម្មតន្ត្រីឈ្មោះ ហង្សមាស ជាម្ចាស់ ។<br>• មិនដឹងអំពីសម្ព័ន្ធភាពនយោបាយ | **ភាសា:** ខ្មែរ<br>**ការផ្សាយ:** ព័ត៌មាន តន្ត្រី និង កម្មវិធីកម្សាន្តផ្សេងៗ |
| **១៨** | សម្បុកឃ្មុំ FM | FM ១០៥ MHz | • លោក ម៉ម សូណង់ដូ<br>• អព្យាក្រឹត្យ | ស្ថានីយវិទ្យុទីមួយ ដែលបានយល់ព្រមលក់ម៉ោងផ្សាយទៅឱ្យវិទ្យុអាស៊ីសេរី សំលេងសហរដ្ឋអាមេរិក និងសំលេងប្រជាធិបតេយ្យ<br>**ភាសា:** ខ្មែរ<br>**ការផ្សាយ:** ព័ត៌មានក្នុងស្រុក |

| | | | | |
|---|---|---|---|---|
| | | | | អព្យាក្រិត្យ<br>**ទីតាំង:** ផ្ទះលេខ ៤៤បេ ផ្លូវ៣៦០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន ភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥)២៣ ២១០ ៤០១<br>ទូរសារ:(៨៥៥)២៣ ២១០ ៤៣៩ |
| **១៩** | អាស៊ីអាគ្នេយ៍ FM | FM១០៦ MHz | • ឯកឧត្តម កៅ គឹមហ៊ួន រដ្ឋលេខាធិការ គណបក្សប្រជាជនកម្ពុជា<br>• គណបក្សប្រជាជនកម្ពុជា | **ភាសា:** ខ្មែរ<br>**ការផ្សាយ:** ព័ត៌មាន និងកម្មវិធីកម្សាន្ត<br>**ទីតាំង:** ភូមិស្វែងរលើង ខណ្ឌសែនសុខ ភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥)២៣ ៩៩៥ ១០៦<br>ទូរសារ: (៨៥៥)២៣ ៩៩៥ ១០៧ |
| **២០** | សារិកា FM | FM១០៦.៥ MHz | • មិនដឹង | **ភាសា:** ខ្មែរ<br>**ការផ្សាយ:** ព័ត៌មាន និងកម្មវិធីកម្សាន្ត<br>**ទីតាំង:** ផ្ទះលេខ ១៤A ផ្លូវ ៣៩២ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥) ៩២ ៥០០ ០៨០ |
| **២១** | ខ្មែរ FM | FM១០៧ MHz | • ឯកឧត្តម ឃុន ហាំង រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា គ្រប់គ្រងដោយ ឃុន អេឡៃណា<br>• គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ីប៉ិច | **ភាសា:** ខ្មែរ<br>**ការផ្សាយ:** តន្ត្រីបែបទំនើប និងព័ត៌មាន<br>**ទីតាំង:** ប្រតិបត្តិដោយទូរទស្សន៍ខ្មែរប៉ុស្តិ៍លេខ ៩ ផ្ទះលេខ ១៨ ផ្លូវលេខ៥៦២ ភ្នំពេញ |

| | | | | |
|---|---|---|---|---|
| | | | | ទូរស័ព្ទ: (៨៥៥)២៣ ៨៨០ ៨៧៤ |
| **២២** | វិទ្យុ ABC | FM១០៧.៥ MHz | • មិនស្គាល់<br>• មិនស្គាល់ | **ភាសា:** ខ្មែរ<br>**ការផ្សាយ:** ការអប់រំស្ដីពីបញ្ហាចរាចរ<br>**ទីតាំង:** ផ្ទះលេខ ៥0A ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ ភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥)២៣ ៨៨២ ៣០៩ ឬ (៨៥៥)១២ ៦៤៤ ៤២៦ |
| **ស្ថានីយវិទ្យុ បរទេស** | | | | |
| **២៣** | បារាំងអន្តរជាតិ RFI | FM ៩២.0MHz | • វិទ្យុបារាំងអន្តរជាតិ<br>• អព្យាក្រិត | **ភាសា:** ភាសាបារាំង និងខ្មែរ<br>**ការផ្សាយ:** ព័ត៌មាន តន្ត្រី និងកម្មវិធីកម្សាន្តផ្សេងៗ<br>**ទីតាំង:** មជ្ឈមណ្ឌលវប្បធម៌បារាំង ផ្ទះលេខ ២១៨ ផ្លូវកែវជា (ផ្លូវ១៨៤ ) ភ្នំពេញ |
| **២៤** | អង់គ្លេស BBC | FM ១០០ MHz | • សាជីវកម្មផ្សាយសម្លេងចក្រភពអង់គ្លេស។<br>• អព្យាក្រិត្យ | **ភាសា:** អង់គ្លេស<br>**ការផ្សាយ:** ផ្សាយព័ត៌មាន និងកម្មវិធីពិភាក្សាពីចក្រភពអង់គ្លេស |
| **២៥** | អូស្ត្រាលី ABC | FM១០១.៥ MHz | • សាជីវកម្មផ្សាយរបស់អូស្ត្រាលី<br>• អព្យាក្រិត្យ | **ភាសា:** អង់គ្លេស<br>**ការផ្សាយ:** ផ្សាយព័ត៌មាន និងកម្មវិធីពិភាក្សាពី អូស្ត្រាលី<br>ទីតាំង: ចំការដូង ភ្នំពេញ |

## តាមបណ្តាខេត្ត

ស្ថានីយវិទ្យុនៅតាមបណ្តាខេត្តនានា គឺជាស្ថានីយផ្សាយបន្តពីភ្នំពេញ ហើយផ្សាយគាំទ្រគណបក្សកាន់អំណាច។ ប៉ុន្តែ ស្ថានីយវិទ្យុមួយចំនួនក៏ជាស្ថានីយអព្យាក្រិត្យដែរដូចជា វិទ្យុឃ្លាំងមឿង និងវិទ្យុបារាំងអន្តរជាតិ នៅខេត្តបាត់ដំបង វិទ្យុអង្គររដ្ឋា (FM 95.5) វិទ្យុ Love FM (FM97.5) (មិនមាននយោបាយ) និងវិទ្យុអង់គ្លេស BBC (FM 99.25) នៅខេត្តសៀមរាប និងវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (FM 93.5) នៅខេត្តស្វាយរៀង ជាដើម ។

ស្ថានីយវិទ្យុបរទេស ដែលផ្សាយបន្តពីភ្នំពេញគឺជាវិទ្យុអព្យាក្រិត្យដែរ ដូចជាវិទ្យុអូស្ត្រាលី ABC, វិទ្យុអង់គ្លេស BBC វិទ្យុបារាំងអន្តរជាតិ RFI វិទ្យុអាស៊ីសេរី RFA និងវិទ្យុសម្លេងសហរដ្ឋអាមេរិក VOA ជាដើម សុទ្ធតែជាវិទ្យុមានប្រជាប្រិយភាពនៅតាមបណ្តាខេត្ត។ ប៉ុន្តែ ភាគច្រើនមិនអាចផ្សាយទៅទីជនបទដាច់ស្រយាលទេ ។

| ល.រ | ស្ថានីយ | រលកធាតុអាកាស | ឈ្មោះ/ពាក្យស្លោក | សម្គាល់ |
|---|---|---|---|---|
| ១ | ខេត្តបាត់ដំបង | ៩០.២៥ MHz | វិទ្យុឃ្លាំងមឿង | ភាសា: បារាំង និងខ្មែរ |
| ២ | | ៩១.0 MHz | វិទ្យុខេមរា | ទីតាំង: ទល់មុខប៉ៃកខាងជើង សណ្ឋាគារប្រាំពីរមករា |
| ៣ | | ៩៤.៥ MHz | វិទ្យុបារាំងអន្តរជាតិ | ភាសា: បារាំង និងខ្មែរ |
| ៤ | | ៩៦.១ MHz | វិទ្យុខេត្តបាត់ដំបង | ទីតាំង: ភូមិអណ្តូងចិន ឃុំអូចា ខេត្តបាត់ដំបង |
| ៥ | | ១០៣.២៥ MHz | វិទ្យុ Sweet FM | សម្ព័ន្ធភាពជាមួយវិទ្យុ FM ១០៣.0 និងទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ៣ |
| ៦ | ខេត្តកំពត | ១០៣.៥ MHz | វិទ្យុខេត្តកំពត (Sweet FM) | សម្ព័ន្ធភាពជាមួយវិទ្យុ FM ១០៣.0 និងទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ៣ និងផ្សាយបន្តពីវិទ្យុ ៩៣.២៥។ |
| ៧ | | ៩៣.២៥ MHz | វិទ្យុខេត្តកំពត (Sweet FM) | សម្ព័ន្ធភាពជាមួយវិទ្យុ FM ១០៣.0 និងទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ៣ ទីតាំង: ភូមិសុវណ្ណសាគរ ស្រុកកំពង់កណ្តាល |

| | | | | |
|---|---|---|---|---|
| | | | | ខេត្តកំពត |
| ៨ | ខេត្តកំពង់ចាម | ៩១.៥ MHz | វិទ្យុបាយ័ន | ផ្សាយបន្តពីវិទ្យុភ្នំពេញ ៩៥.0 |
| ៩ | | ៩២.៥ MHz | វិទ្យុខេត្តកំពង់ចាម | ទីតាំង: ភូមិ៣ វាលវង់ ខេត្តកំពង់ចាម |
| ១០ | | ៩៤.៥ MHz | វិទ្យុ RFI | ភាសា: បារាំង/ខ្មែរ |
| ១១ | | ១00.៥ MHz | វិទ្យុ FM ១00.៥ (Sweet FM) | ទីតាំង: បរិវេណគណបក្សប្រជាជនកម្ពុជា ទល់មុខសណ្ឋាគារមិត្តភាព ផ្លូវកុសុមៈនារី ។ សម្ព័ន្ធភាពជាមួយវិទ្យុ១0៣.0 និងទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ៣ |
| ១២ | ខេត្តកំពង់ធំ | ៨៨.៥ MHz | វិទ្យុគណបក្សហ៊្វុនស៊ិនប៉ិច | ទីតាំង: ព្រៃតាហ៊ូ ស្ទឹងសែន ខេត្តកំពង់ធំ |
| ១៣ | | ៩១.៥ MHz | វិទ្យុបាយ័ន | ផ្សាយបន្តពីស្ថានីយវិទ្យុភ្នំពេញ ៩៥.0 |
| ១៤ | | ៩៥.0 MHz | វិទ្យុបាយ័ន | សម្ព័ន្ធភាពជាមួយវិទ្យុ ៩៥.0 និងផ្សាយបន្តពីស្ថានីយវិទ្យុភ្នំពេញ ៩៥.0<br>ទីតាំង: ស្ទឹងសែន ខេត្តកំពង់ធំ |
| ១៥ | | ៩៨.៣ MHz | វិទ្យុជាតិ | ទីតាំង: ស្ទឹងសែន ខេត្តកំពង់ធំ<br>គ្រប់គ្រងដោយក្រសួងព័ត៌មាន |
| ១៦ | | ១0២.២ MHz | វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា | កម្មវិធី ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ និងផ្សាយបន្តពីវិទ្យុ FM ១0២ នៅភ្នំពេញ |
| ១៧ | | ១0៧.៣ MHz | វិទ្យុខេត្តកំពង់ធំ | |
| ១៨ | ប៉ៃលិន | ៩0.៥ MHz | វិទ្យុប៉ៃលិន | ទីតាំង: ភូមិចំការកាហ្វេ ទួលល្វា ប៉ៃលិន |
| ១៩ | ខេត្តព្រះវិហារ | ៩៩.0 MHz | វិទ្យុព្រះវិហារ (Sweet FM) | សម្ព័ន្ធភាពជាមួយវិទ្យុ FM ១0៣ និងទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ៣<br>ទីតាំង: ភូមិស្រអែម ឃុំកន្ទួត ស្រុកចមក្សាន្ត |
| ២0 | ខេត្តពោធិ៍សាត់ | ៩៨.៥ MHz | វិទ្យុខេត្តពោធិ៍សាត់ | |
| ២១ | | ៩២.0 MHz | វិទ្យុ RFI | ភាសា: បារាំង |
| ២២ | | ៩៣.0 MHz | វិទ្យុបាយ័ន FM ៩៣ | ទីតាំង: ភូមិកាសាកម្ម ឃុំស្រង៉ែ ខេត្តសៀមរាប |
| ២៣ | | ៩៥.៥ MHz | វិទ្យុអង្គររដ្ឋ | |

| | | | | |
|---|---|---|---|---|
| ២៤ | ខេត្តសៀមរាប | ៩៧.៥ MHz | វិទ្យុ LOVE FM | ភាសា: ខ្មែរ និងអង់គ្លេស<br>ផ្សាយបន្តព័តិមានភាសាអង់គ្លេសពីវិទ្យុអូស្ត្រាលី |
| ២៥ | | ៩៨.0 MHz | វិទ្យុ FM Hotwave | សម្ព័ន្ធភាពជាមួយវិទ្យុ ៩៨.0 និងទូរទស្សន៍កងយោធពលខេមរភូមិន្ទប៉ុស្តិ៍លេខ ៥<br>ទីតាំង: មណ្ឌល៣ ភូមិស្លក្រាម ខេត្តសៀមរាប<br>ទូរស័ព្ទ: (៨៥៥)៦៣ ៣៨0 ៤៥៥ |
| ២៦ | | ៩៩.២៥ MHz | វិទ្យុសកល BBC (FM ១00) | ភាសា: អង់គ្លេស |
| ២៧ | | ១00.៥ MHz | វិទ្យុខេត្តសៀមរាប (Sweet FM) | សម្ព័ន្ធភាពជាមួយវិទ្យុ FM ១0៣ និងទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ៣<br>ទីតាំង: ភូមិមណ្ឌល២ ស្វាយដង្គុំ ខេត្តសៀមរាប |
| ២៨ | | ១0១.៥ MHz | វិទ្យុអូស្ត្រាលី ABC | ភាសា: អង់គ្លេស |
| ២៩ | | ១0២.៥ MHz | វិទ្យុក្រុងសៀមរាប | ទីតាំង: នៅក្រោយស្តាតចាស់ |
| ៣0 | ខេត្តព្រះសីហនុ | ៩២.00 MHz | វិទ្យុបាយ័ន | ផ្សាយបន្តពីវិទ្យុភ្នំពេញ ៩៥.0 ដែលជាញឹកញាប់ផ្សាយអំពីសេចក្តីប្រកាសក្នុងស្រុក |
| ៣១ | | ៩៤.៥ MHz | វិទ្យុ RFI | ភាសា: បារាំង/ខ្មែរ |
| ៣២ | | ១00.៥ MHz | វិទ្យុខេត្តព្រះសីហនុ (Sweet FM) | សម្ព័ន្ធភាពជាមួយវិទ្យុ FM ១0៣ និងទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ៣<br>ទីតាំង: ផ្ទះលេខ១៦៩ ផ្លូវឯករាជ្យ ខេត្តព្រះសីហនុ |
| ៣៣ | ខេត្តបន្ទាយមានជ័យ | ៩0.២៥ MHz | វិទ្យុ ៩0.២៥ | ផ្សាយបន្តពីវិទ្យុភ្នំពេញ ៩0.0 |
| ៣៤ | | ៩៦.៥ MHz | វិទ្យុខេត្តបន្ទាយមានជ័យ (FM ៩៦.៥) | ទីតាំង: ភូមិភ្នំស្វាយ ភូមិគូថាន់ ឃុំអូរអំពិល ស្រុកសិរីសុផុន ខេត្តបន្ទាយមានជ័យ |
| ៣៥ | ខេត្តស្វាយរៀង | ៩៣.៥ MHz | វិទ្យុមណ្ឌលព័តិមានស្ត្រីកម្ពុជា | សម្ព័ន្ធភាពជាមួយវិទ្យុមណ្ឌលព័តិមានស្ត្រីកម្ពុជានៅភ្នំពេញ FM ១0២ |
| ៣៦ | | ៩៨.៧៥ MHz | វិទ្យុបាយ័ន FM | ផ្សាយបន្តពីវិទ្យុនៅភ្នំពេញ ៩៥.0 |

| | | | | |
|---|---|---|---|---|
| ៣៧ | | ១០៣.៧៥ MHz | វិទ្យុខេត្តស្វាយរៀង (Sweet FM) | ទីតាំង: ភូមិមេភ្លៀង ខេត្តស្វាយរៀង |
| ៣៨ | ខេត្តស្ទឹងត្រែង | ៩២.0 MHz | វិទ្យុបាយ័ន FM | ផ្សាយបន្តពីវិទ្យុនៅភ្នំពេញ ៩៥.0 |
| ៣៩ | ខេត្តតាកែវ | ៩២.៥ MHz | វិទ្យុគោកធ្លក | |
| ៤0 | ខេត្តក្រចេះ | ៩១.0 MHz | វិទ្យុបាយ័ន FM | ផ្សាយបន្តពីវិទ្យុនៅភ្នំពេញ ៩៥.0 |

## សារព័ត៌មាន

សារព័ត៌មានប្រចាំថ្ងៃកោះសន្តិភាព រស្មីកម្ពុជា និងកម្ពុជាថ្មី គឺជាសារព័ត៌មាន ៣ ដែលលក់ដាច់ជាងគេបំផុត ដែលសារព័ត៌មាននីមួយៗ អាចលក់បានពី ២០.000 ទៅ ២៥.000 ច្បាប់ក្នុងមួយថ្ងៃ។ ចំណែកសារព័ត៌មានតូចៗភាគច្រើន អាចបោះពុម្ពលក់ត្រឹមតែរាប់ពាន់ច្បាប់តែប៉ុណ្ណោះ ប៉ុន្តែចំនួននេះ អាចកើនឡើង ឬ ថយចុះទៅតាមស្ថានភាពព័ត៌មានប្រចាំថ្ងៃ ហើយការលក់បានច្រើន គឺនៅពេលជិតបោះឆ្នោត និងពេលមានបញ្ហានយោបាយក្នុងប្រទេសជាដើម។

សារព័ត៌មានប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ភាគច្រើនផ្សាយព័ត៌មានទូទៅ និងនយោបាយ កីឡា ពាណិជ្ជកម្ម និងអត្ថបទនានាដកស្រង់ចេញពីសៀវភៅជាដើម។ សារព័ត៌មានដែលលក់ដាច់ភាគច្រើន ធ្វើការប្រកួតប្រជែង ដណ្តើមអ្នកអានតាមរយៈការផ្សាយនៅលើទំព័រទី១របស់ខ្លួន ដោយប្រើប្រាស់ចំណងជើងដែលមានការចាប់អារម្មណ៍ និងរូបភាពគួរឱ្យឆ្អើម ការកាប់សម្លាប់ និងគ្រោះថ្នាក់ចរាចរ ដើម្បីឱ្យមានការទាក់ទាញ។ ការធ្វើបែបនេះ គឺជាការសំខាន់ណាស់ ពីព្រោះមានតែសារព័ត៌មានតិចតួចប៉ុណ្ណោះ ដែលមានជាប្រព័ន្ធត្រឹមត្រូវក្នុងការជាវទិញជាប្រចាំ ដូច្នេះហើយការលក់ភាគច្រើនអាចលក់បាន តាមតូបលក់សារព័ត៌មាននៅតាមផ្លូវសាធារណៈ និងតាមស្តង់នៅផ្សារនានា។ ការជ្រើសរើសរបស់អ្នកអាន គឺអាស្រ័យទៅលើនិន្នាការនយោបាយរបស់គេ (ខ្លះចង់អានសារព័ត៌មានគាំទ្ររដ្ឋាភិបាល និងខ្លះទៀតអានសារព័ត៌មានជំទាស់) ប៉ុន្តែ បណ្ណាធិការភាគច្រើននិយាយថា អ្នកអានភាគច្រើនមានការស្មោះស្ម័គ្រតិចតួចណាស់ក្នុងការគាំទ្រសារព័ត៌មានណាមួយឱ្យបានច្បាស់លាស់នោះ។ តាមមើលទៅ អ្នកអានសារព័ត៌មានច្រើនតែទៅរើករកមើលសារព័ត៌មានណាដែលមានរូបភាពល្អនៅលើទំព័រដំបូងរបស់សារព័ត៌មាននោះ ដែលបញ្ហានេះអាច

នាំឱ្យមានការប្រកួតប្រជែងយ៉ាងខ្លាំង ក្នុងការចុះផ្សាយនៅលើទំព័រនេះ ដើម្បីប្រកួតប្រជែងទាក់ទាញអ្នកអានឱ្យទិញសារព័ត៌មានរបស់ខ្លួន[៣] ។

គ្មានសារព័ត៌មានភាសាខ្មែរណាមួយដែលអាចចាត់ទុកថា ជាសារព័ត៌មានអព្យាក្រិត្យខាងនយោបាយទេ។ តាមពិត ស្ទើរតែគ្រប់សារព័ត៌មានទាំងអស់ ទាំងតូច ទាំងធំ គឺជារបស់ ឬ គាំទ្រដោយអ្នកនយោបាយមានអំណាច ឬ ពាណិជ្ជករណាម្នាក់ ហើយសារព័ត៌មានទាំងនោះ ច្រើនតែឆ្លុះបញ្ចាំងនូវទស្សនៈនយោបាយលំអៀងរបស់ ចៅហ្វាយរបស់សារព័ត៌មាននោះ នៅក្នុងខ្លឹមសារ អត្ថបទបណ្ណាធិការ។ ចំពោះសារព័ត៌មានតូចៗ ចៅហ្វាយ និងបណ្ណាធិការរបស់គេ អាចមានការផ្លាស់ប្តូរជាញឹកញាប់។ នៅក្នុងឆ្នាំ ២០០០ បើចង់ទិញសារព័ត៌មានណាមួយឱ្យមានការគាំទ្រ នោះគ្រាន់តែចំណាយតិចតួចត្រឹមតែ ៤០០ ដុល្លាអាមេរិក ក្នុងមួយខែប៉ុណ្ណោះ ហើយចេញផ្សាយពីរទៅបីដងក្នុងមួយសប្តាហ៍ ប៉ុន្តែសព្វថ្ងៃនេះមិនដឹងថាត្រូវចំណាយប៉ុន្មានទេ ដើម្បីទិញការគាំទ្រនោះ ពីសារព័ត៌មានតូចៗបែបនេះ[៤] ។

អ្នកសារព័ត៌មានកម្ពុជា ជាធម្មតាបែងចែកសារព័ត៌មានជា ៣ ប្រភេទគឺ សារព័ត៌មានគាំទ្ររដ្ឋាភិបាល សារព័ត៌មានខាងជំទាស់ និងសារព័ត៌មានអន្តរជាតិ ។ សារព័ត៌មានអន្តរជាតិគេសំដៅទៅលើសារព័ត៌មានដូចជា ឌឺ ឃែម បូឌា ដេលី ភ្នំពេញប៉ុស្តិ៍ និង កំបូជស័រ ជាដើម ហើយក្រៅពីនោះក៏នៅមានសារព័ត៌មានភាសាចិន យ៉ាងច្រើនទៀតដែរ ដែលភាគច្រើនផ្សាយតែព័ត៌មានពាណិជ្ជកម្ម។ សារព័ត៌មានអន្តរជាតិច្រើនតែជាសារព័ត៌មានឯករាជ្យ ទោះបីជាថ្មីៗនេះមានការផ្លាស់ប្តូរជំនឿបែបនេះខ្លះៗក៏ដោយ។ អ្នកសារព័ត៌មានខ្មែរភាគច្រើនចង់បានសេរីភាព និងកិច្ចការពារបានខ្លះៗ ព្រមទាំង( ប្រាក់បៀវត្សរ៍ខ្ពស់ជាង) ដូចដែលបុគ្គលិកធ្វើការឱ្យសារព័ត៌មានអន្តរជាតិទទួលបាន។

សារព័ត៌មានគាំទ្ររដ្ឋាភិបាល និងសារព័ត៌មានជំទាស់ ច្រើនតែប្រើប្រាស់ទំព័រសារព័ត៌មាន ដើម្បីផ្សព្វផ្សាយគណបក្សនយោបាយរៀងៗខ្លួន និងដើម្បីវាយប្រហារបច្ចាមិត្តផង។ សារព័ត៌មានគាំទ្រដែលរដ្ឋាភិបាល ច្រើនតែមិនផ្សាយព្រឹត្តិការណ៍ព័ត៌មានសំខាន់ៗនានាទេ ប្រសិនបើគេគិតថាជារឿងអាម៉ាស់ ឬធ្វើឱ្យប៉ះពាល់ដល់អំណាច ឬ ផ្សាយប្រើប្រាស់ពាក្យពេចន៍ដោយប្រុងប្រយ័ត្នជាទីបំផុត មិនហ៊ានឱ្យប៉ះពាល់ដល់រដ្ឋាភិបាលឡើយ។ ចំណែកឯសារព័ត៌មានជំទាស់វិញ បច្ចុប្បន្នច្រើនតែផ្សាយចោទប្រកាន់រដ្ឋាភិបាល

---

[៣] ការវិភាគអំពីទម្លាប់ការទិញនេះ គឺផ្អែកលើការសម្ភាសន៍ជាមួយអ្នកឃ្លាំមើលសារព័ត៌មាន និងអ្នកសារព័ត៌មាន។

[៤] Britt-Loise Edman ជាប់គាំងក្នុងអតីតកាល ស្វែងរកអនាគត: ការសិក្សាអំពីផ្នែកសារព័ត៌មានកម្ពុជា ផ្តល់ដោយ Sida និង Forum Syd ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០០ ទំព័រ ១៨។

ហើយជូនកាលមិនសូវមានភស្តុតាងជាក់ស្តែងច្រើនប៉ុន្មានទេ ព័ត៌មានទាំងនោះច្រើនតែចោទប្រកាន់មន្ត្រីរដ្ឋាភិបាល និងបក្សពួករបស់មន្ត្រីទាំងនោះ។

| ល.រ | សារព័ត៌មាន | ម្ចាស់/អ្នកគ្រប់គ្រង | លំអៀងនយោបាយ | រយៈពេលចេញ |
|---|---|---|---|---|
| ១ | អរិយធម៌ | ▪ ស្វួន និមល[៥] | គណបក្សប្រជាជនកម្ពុជា | |
| ២ | ស និង ខ្មៅ | ▪ ជិន ច័ន្ទមុន្នី | អព្យាក្រឹត្យ/គណបក្សប្រជាជនកម្ពុជា[៦] | ១ដង/១សប្តាហ៍ |
| ៣ | ចក្រវាលប្រចាំថ្ងៃ | ▪ កែវ សោភ័ណ ជាពាណិជ្ជករ | គណបក្សប្រជាជនកម្ពុជា | ៣ដង/១សប្តាហ៍ |
| ៤ | ជួយខ្មែរ | ▪ វង្ស សុភាព | គណបក្សសម រង្ស៊ី | ៥ដង/១សប្តាហ៍ |
| ៥ | ដើមអំពិល | ▪ សយ សុភាព ធ្វើការនៅទូរទស្សន៍ស៊ីធីអិនដែរ | គណបក្សប្រជាជនកម្ពុជា | ៦ដង/១សប្តាហ៍ |
| ៦ | ដើមត្នោត | ▪ ហុក រ៉េន | គណបក្សសម រង្ស៊ី | ២ដង/១សប្តាហ៍ |
| ៧ | កម្ពុជាថ្មី | ▪ លី ហួរ | គណបក្សប្រជាជនកម្ពុជា | ៦ដង/១សប្តាហ៍ |
| ៨ | ខ្មែរអមតៈ | ▪ ប៊ុន ថា ទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ | គណបក្សនរោត្តម រណឫទ្ធិ | ១ដង/១សប្តាហ៍ |
| ៩ | ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ▪ ហួម រាជចំរើន | គណបក្សប្រជាជនកម្ពុជា | ៦ដង/១សប្តាហ៍ |
| ១០ | ខ្មែរម្ចាស់ស្រុក | ▪ ស្ពុញ លុយ | គណបក្សសម រង្ស៊ី | ២ដង/១សប្តាហ៍ |

[៥] ស្វួន និមល គឺជាឈ្មោះនៅក្នុងបញ្ជីក្រសួងព័ត៌មាន ប៉ុន្តែ អ្នកសារព័ត៌មានជាន់ខ្ពស់ពីរនាក់ គិតថាសារព័ត៌មាននេះគ្រប់គ្រងដោយ ព្រំ សាយ។

[៦] មានយោបល់ខ្វែងគ្នាក្នុងចំណោមអ្នកសារព័ត៌មានជាន់ខ្ពស់ អំពីលំអៀងនយោបាយនៃសារព័ត៌មាន។

| | | | | |
|---|---|---|---|---|
| ១១ | ខ្មែរស្ថាបនា | ▪ វង់ សម័យ | គណបក្សប្រជាជនកម្ពុជា | ៦ដង/១សប្តាហ៍ |
| ១២ | កោះសន្តិភាព | ▪ ប៊ុន សារឿន<br>▪ ថុង សុវណ្ណរង្សី | គណបក្សប្រជាជនកម្ពុជា | ៦ដង/១សប្តាហ៍ |
| ១៣ | មិត្តអ្នក | ▪ តាំង ឈុនលឹម | គណបក្សប្រជាជនកម្ពុជា | ១ដង/១សប្តាហ៍ |
| ១៤ | មាតុភូមិ | ▪ មិនដឹង | | ២ដង/១សប្តាហ៍ |
| ១៥ | មេគង្គកម្ពុជា | ▪ គង់ សុទ្ធា | គណបក្សហ៊្វុនស៊ិនប៉ិច | |
| ១៦ | មនសិការខ្មែរ | ▪ ដាំ សិទ្ធិ អគ្គលេខាធិការរង នៃ គណបក្ស សម រង្ស៊ី | គណបក្សសម រង្ស៊ី | ៦ដង/១សប្តាហ៍ |
| ១៧ | រស្មីអង្គរ | ▪ ឥន ចាន់ស៊ីវុត្ថា | គណបក្សប្រជាជនកម្ពុជា | |
| ១៨ | រស្មីកម្ពុជា | ▪ ផ្លុង ជុំ<br>▪ ប៉ែន ផេង | គណបក្សប្រជាជនកម្ពុជា | ៦ដង/១សប្តាហ៍ |
| ១៩ | សម្លេងយុវជនខ្មែរ | ▪ កែវ សុធា | គណបក្សនរោត្តម រណឫទ្ធិ | ៦ដង/១សប្តាហ៍ |
| ២០ | សម្លេងយុវវ័យ | ▪ លី ប៊ុនណា | គណបក្សប្រជាជនកម្ពុជា | ៣ដង/១សប្តាហ៍ |
| ២១ | សម្រែកកូនខ្មែរ | ▪ ប៉ក់ សារិទ្ធ | | ២ដង/១សប្តាហ៍ |
| ២២ | ស្មាដៃក្មេងវត្ត | ▪ សំ ផាន់ណារិទ្ធ | គណបក្សប្រជាជនកម្ពុជា | |
| ២៣ | សុជីវធម៌ | ▪ ជ័យ យ៉ាណូ | | ១ដង/១សប្តាហ៍ |
| ២៤ | វត្តភ្នំ | ▪ មិនដឹង | គណបក្សហ៊្វុនស៊ិនប៉ិច | ៦ដង/១សប្តាហ៍ |
| ២៥ | ឌឺ ឃែមបូឌា ដេលី | ▪ បរទេស | អព្យាក្រិត | ៦ដង/១សប្តាហ៍ |
| ២៦ | ភ្នំពេញប៉ុស្តិ៍ | ▪ បរទេស | អព្យាក្រិត | ៦ដង/១សប្តាហ៍ |
| ២៧ | កំបូដស័រ | ▪ បរទេស | អព្យាក្រិត | ១ដង/១សប្តាហ៍ |

## អ៊ីនធឺណិត

ប្រព័ន្ធផ្សាយព័ត៌មានអ៊ីនធឺណិតក្រៅផ្លូវការទើបតែលេចឡើងនៅកម្ពុជាប៉ុន្មានឆ្នាំថ្មីនេះតែប៉ុណ្ណោះ ហើយជាមធ្យម ទទួលបានបទបញ្ញត្តិតិចតួចជាងប្រព័ន្ធផ្សាយព័ត៌មានដែលធ្លាប់មានពីមុន ដែលប្រព័ន្ធនេះ

អាចផ្សាយបានទូលំទូលាយ និងឯករាជ្យជាងគេ។ មានគេហទំព័រមួយចំនួន ដែលអាចផ្សាយព័ត៌មាន និង បទវិចារណកថាឯករាជ្យអំពីនយោបាយ និងបរិយាកាសសង្គមនៅកម្ពុជា។ បញ្ហាដែលរដ្ឋាភិបាលមិនសូវចាប់អារម្មណ៍ក្នុងការដាក់កំហិតលើអ៊ីនធឺណិតនេះ អាចមកពីយល់ថា ប្រជាពលរដ្ឋកម្ពុជាភាគច្រើនមិនអាចប្រើប្រាស់អ៊ីនធឺណិតបានទេ។ តាមការវិភាគមានប្រហែលជា ៤.៤០០នាក់ ប៉ុណ្ណោះទេដែលអាចប្រើប្រាស់បាន ឬ ០.៣%ប៉ុណ្ណោះ ក្នុងចំណោមប្រជាពលរដ្ឋទូទាំងប្រទេស[៧]។ ដោយសារតែមានតម្លៃខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធអន់ថយ នោះនាំឱ្យប្រព័ន្ធផ្សាយព័ត៌មានឯករាជ្យមួយនេះ អាចផ្សាយទៅដល់តែប្រជាពលរដ្ឋមួយក្តាប់តូចតែប៉ុណ្ណោះ។

| ល.រ | ឈ្មោះ និងគេហទំព័រ | ព័ត៌មានបន្ថែម |
|---|---|---|
| **ភាសាបរទេស** | | |
| ១ | បញ្ញវ័ន្តខ្មែរ (Khmer Intelligence)<br>http://www.ki-media.blogspot.com\ | ▪ ជាគេហទំព័រល្បី តែមិនមានបង្ហាញឈ្មោះអ្នកគ្រប់គ្រង ហើយត្រូវបានគេរាយការណ៍ថា គេហទំព័រ នេះ រៀបរៀងដោយខ្មែរមួយក្រុមដែលរស់នៅបរទេស។ គេហទំព័រនេះ ធ្វើការដកស្រង់អត្ថបទព័ត៌មានពីប្រព័ន្ធផ្សាយព័ត៌មានជាតិ និងអន្តរជាតិ ដោយបកប្រែជាភាសាអង់គ្លេស។ |
| ២ | ខ្មែររូបនីយកម្ម (Khmerization)<br>http://www.khmerization.blogspot.com/ | ▪ ខ្មែររូបនីយកម្ម (ដំណើរការដោយខ្មែររស់នៅប្រទេសអូស្ត្រាលី) ដោយដកស្រង់អត្ថបទព័ត៌មានបកប្រែជាភាសាអង់គ្លេស ហើយកែប្រែ និងបន្ថែម ព័ត៌មានរាល់ថ្ងៃ។ |
| ៣ | ឌឹ ខែមបូឌា ដេលី (The Cambodia Daily)<br>http://www.cambodiadaily.com/ | ▪ ជាគេហទំព័រសារព័ត៌មានប្រចាំថ្ងៃ មានព័ត៌មានជាភាសាអង់គ្លេស ប៉ុន្តែមិនបានកែប្រែជាទ្បេងទាត់ទេ។ |
| ៤ | ភ្នំពេញប៉ុស្តិ៍ (Phnom Penh Post) | ▪ ជាគេហទំព័រសារព័ត៌មានប្រចាំថ្ងៃ មានព័ត៌មានជា |

[៧] ស្ថិតិនេះត្រូវបានប្រើយ៉ាងទូលំទូលាយ ហើយមានប្រភពចេញពីសហព័ន្ធទូរគមនាគមន៍អន្តរជាតិ នៃអង្គការសហប្រជាជាតិ ប៉ុន្តែមិនច្បាស់ថាគេគណនារបៀបណាទេ។

| | | |
|---|---|---|
| | http://www.phnompenhpost.com | ភាសាអង់គ្លេស ប៉ុន្តែ កែប្រែ និងបន្ថែមព័ត៌មានរាល់ថ្ងៃ។ |
| ៥ | សំលេងសហរដ្ឋអាមេរិក ជាភាសាខ្មែរ (VOA)<br>http://www.voanews.com/khmer | ▪ ជាគេហទំព័ររបស់វិទ្យុផ្សាយសម្លេង ជាភាសាខ្មែររបស់សហរដ្ឋអាមេរិក។<br>នៅក្នុងគេហទំព័រនេះមាន អត្ថបទព័ត៌មានសរសេរ និងព័ត៌មានសោតទស្សន៍ជាតិ និងអន្តរជាតិ ដោយកែប្រែ និងបន្ថែមជារៀងរាល់ថ្ងៃ។ គេហទំព័រនេះក៏អាចមើលបានជាភាសាខ្មែរដែរ។<br>▪ វិទ្យុសម្លេងសហរដ្ឋអាមេរិក ក៏ធ្វើការផ្សាយជាភាសាខ្មែរជាប្រចាំ តាមរយៈវិទ្យុសម្បុកឃ្មុំ FM ១០៥។ |
| ៦ | សារព័ត៌មាន (Ka-Set)<br>http://cambodia.ka-set.info | ▪ ជាគេហទំព័រព័ត៌មានឯករាជ្យ និងធ្វើការកែប្រែព័ត៌មានជាប្រចាំអំពីព័ត៌មានទូទៅនៅប្រទេសកម្ពុជានិងអំពីប្រជាជនកម្ពុជារស់នៅក្រៅប្រទេស<br>▪ គេហទំព័រនេះមានទាំងភាសាខ្មែរ អង់គ្លេស និងបារាំង<br>▪ បង្កើតដោយអតីតបុគ្គលិកសារព័ត៌មាន មួយចំនួននៃសារព័ត៌មានកំបូឌស័រ។ |
| ៧ | កំបូដស័រ (Cambodge Soir)<br>http://www.cambodgesoir.info | ▪ ជាគេហទំព័ររបស់សារព័ត៌មានភាសាបារាំង ចេញផ្សាយរៀងរាល់សប្តាហ៍ ហើយកែប្រែ និងបន្ថែមព័ត៌មានរាល់ថ្ងៃ។ |
| ៨ | កញ្ចក់ខ្មែរ (The Cambodian Mirror)<br>http://cambodiamirror.wordpress.com | ▪ ផ្សាយជាភាសាខ្មែររៀងរាល់សប្តាហ៍ ក្រោមវិចារណកថា របស់អ្នកសារព័ត៌មានបរទេស។ |
| ៩ | វិទ្យុអាស៊ីសេរី (RFA)<br>http://www.rfa.org/english/news/cambodia | ▪ ជាគេហទំព័ររបស់វិទ្យុអាស៊ីសេរីជាភាសាខ្មែរ។<br>នៅក្នុងគេហទំព័រនេះមានអត្ថបទសរសេរ និងព័ត៌មានសោតទស្សន៍ជាតិ និងអន្តរជាតិ ហើយ |

| | | |
|---|---|---|
| | | កែប្រែ និងបន្ថែមព័ត៌មានរាល់ថ្ងៃ។ គេហទំព័រនេះក៏អាចមើលបានជាភាសាខ្មែរដែរ។<br>▪ វិទ្យុអាស៊ីសេរីក៏ធ្វើការផ្សាយជាប្រចាំតាមរយៈវិទ្យុសម្បុកឃ្មុំ FM ១០៥។ |
| **ភាសាខ្មែរ** | | |
| ១០ | កោះសន្តិភាព (Koh Santepheap Daily)<br>http://www.kohsantepheapdaily.com.kh | ▪ ជាគេហទំព័រល្បី របស់សារព័ត៌មានជាភាសាខ្មែរ ហើយធ្វើការកែប្រែ និងបន្ថែមព័ត៌មានរៀងរាល់ថ្ងៃ។<br>▪ លក្ខណៈពិសេសនៃព័ត៌មានទូទៅ និងនយោបាយ កីឡា សេដ្ឋកិច្ច និងអត្ថបទ ដកស្រង់ចេញពីសៀវភៅ។ |
| ១១ | អេ វើ រី ឌេ (Everyday)<br>http://www.everyday.com.kh | ▪ ជាគេហទំព័រពាណិជ្ជកម្ម សំរាប់អ្នកផ្តល់សេវាកម្មអ៊ីនធឺណិត<br>▪ មានព័ត៌មានជាតិ និងអន្តរជាតិ ដកស្រង់ចេញពីប្រភពផ្សេងៗគ្នា (មានជាភាសាអង់គ្លេសផងដែរ)។ |
| ១២ | ជាតិខ្មែរ (Khmer Nation)<br>http://www.kn-news.blogspot.com | ▪ ជាគេហទំព័ររបស់សារព័ត៌មានជាតិខ្មែរ ដែលមាននិន្នាការទៅរកគណបក្សសម រង្ស៊ី<br>▪ មានព័ត៌មានថ្មីៗ ដែលឆ្លុះបញ្ចាំងពីទស្សនៈគណបក្សជំទាស់។ |
| ១៣ | នយោបាយប្រទេសកម្ពុជា (Cambodia Politic)<br>http://www.cambodiapolitic.org | ▪ គេហទំព័រនេះបង្កើតដោយក្រុមមិនចេញមុខ ចេញផ្សាយព័ត៌មានអំពីនយោបាយប្រទេសកម្ពុជា<br>▪ មានភ្ជាប់អាសយដ្ឋាន របស់គេហទំព័រដទៃទៀត និងគណបក្សនយោបាយជាច្រើន នៅក្នុងប្រទេសកម្ពុជា។ |
| ១៤ | សារព័ត៌មានព្រៃនគរ (The Preynokor News)<br>http://www.preynokornews.blogspot.com | ▪ ជាគេហទំព័រដែលផ្សាយ អំពីបញ្ហារបស់ខ្មែរកម្ពុជា |

| | | |
|---|---|---|
| | | ក្រោម<br>▪ ហើយធ្វើការកែប្រែ និងបន្ថែមជារៀងរាល់សប្តាហ៍។ |
| ១៥ | វិទ្យុសម្លេងខ្មែរកម្ពុជាក្រោម (The Voice of Kampuchea Krom Radio)<br>http://vokk.net | ▪ ជាគេហទំព័ររបស់វិទ្យុសម្លេងខ្មែរកម្ពុជាក្រោម ផ្សាយព័ត៌មាន និងព័ត៌មានទាក់ទងនឹងប្រជាពលរដ្ឋកម្ពុជាក្រោម។ |
| ១៦ | សារព័ត៌មានដើមអំពិល (Deum Ampil News)<br>http://www.dap-news.com | ▪ ជាគេហទំព័ររបស់សារព័ត៌មានដើមអំពិល ដែលធ្វើការកែប្រែ និងបន្ថែមជារៀងរាល់ថ្ងៃ |
| ១៧ | ខ្មែរវិភាគ (Khmer Analyst)<br>http://khmervipheak.wordpress.com | ▪ ជាគេហទំព័រដែលមានព័ត៌មានថ្មីៗអំពីប្រទេសកម្ពុជា ដកស្រង់ចេញពីប្រភពផ្សេងៗ។ |
| ១៨ | ខ្មែរស្ថាបនា (Khmer Staphana)<br>http://www.ksn-news.com | ▪ ជាគេហទំព័ររបស់សារព័ត៌មានខ្មែរស្ថាបនា ដែលចេញផ្សាយ និងកែប្រែ ព្រមទាំងបន្ថែមរៀងរាល់ថ្ងៃ។ |

□□□

# ៣. ការគំរាមកំហែងលើប្រព័ន្ធផ្សាយព័ត៌មាន

## ឃាតកម្ម

### លោក ធូ ចាន់មង្គល *ស្លាប់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៤*

លោក ធូ ចាន់មង្គល ជានិពន្ធនាយកនៃសារព័ត៌មានអន្តរាគមន៍ ដែលចេញផ្សាយពីរសប្តាហ៍ម្តង បានស្លាប់មួយថ្ងៃក្រោយពីជួបប្រទះឃើញលោកសន្លប់ ដោយសាររបួសក្បាលនៅតាមផ្លូវមួយនៃទីក្រុងភ្នំពេញ។ ជាដំបូងនគរបាលបានអះអាងថា លោកជាជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរ ប៉ុន្តែគេពុំឃើញមានរបួសណាផ្សេងទៀតលើរូបរាងកាយរបស់លោកឡើយ ហើយម៉ូតូរបស់លោកក៏មិនឃើញមានស្នាមឆ្កូតដែរ។ មុននឹងលោក មង្គល ស្លាប់ សារព័ត៌មានអន្តរាគមន៍បានចុះផ្សាយអត្ថបទជាច្រើនចោទប្រកាន់រដ្ឋាភិបាល និងមន្ត្រីយោធាមួយចំនួនថាបានប្រព្រឹត្តអំពើពុករលួយ ហើយការិយាល័យសារព័ត៌មាននេះបានក្លាយជាគោលដៅនៃការវាយប្រហារដោយគ្រាប់បែក ក្នុងខែមីនា។

### លោក នន់ ចាន់ *ត្រូវបាញ់ស្លាប់ នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៤*

លោក នន់ ចាន់ ជាបណ្ណាធិការនៃសារព័ត៌មានសម្លេងយុវជនខ្មែរ ត្រូវបានជនមិនស្គាល់មុខបាញ់សម្លាប់នៅភ្នំពេញ។ លោក និងបុគ្គលិកសារព័ត៌មានមួយចំនួនទៀតបានរាយការណ៍ថា បានទទួលការគំរាមកំហែងដល់អាយុជីវិតមុននឹងឃាតកម្មនេះបានកើតឡើង។ សារព័ត៌មានរបស់លោកបានរិះគន់គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ហើយធ្លាប់បានទទួលការព្រមានជាលាយល័ក្ខអក្សរពីក្រសួងព័ត៌មាន ។



មួយថ្ងៃក្រោយឃាតកម្មរបស់លោក នន់ ចាន់ លោករដ្ឋលេខាធិការក្រសួងព័ត៌មានបានមានប្រសាសន៍ថា : "ប្រសិនបើលោកមិនត្រូវបានធ្វើឃាតទេ យើងនឹងត្រូវប្តឹងលោក នន់ ចាន់"។

ជនសង្ស័យពីរនាក់ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងឃាតកម្មនេះ ហើយតាមរបាយការណ៍ថា ជនទាំងពីរបានសារភាពទោសកំហុស ប៉ុន្តែក្រោយមកស្រាប់តែមានការលើកលែងការចោទប្រកាន់ទៅវិញ។ គ្មានព័ត៌មានអំពីអ្នកណាបញ្ជាឱ្យមានការសម្លាប់នេះត្រូវបានលាតត្រដាងឡើយ ។

### **លោក ចាន់ ដារ៉ា** *បាញ់ស្លាប់ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៤*



លោក ចាន់ ដារ៉ា គឺជាអ្នកឆ្លើយឆ្លងព័ត៌មានជាមួយសារព័ត៌មានកោះសន្តិភាព ហើយក៏រួមចំណែក ជាមួយសារព័ត៌មានផ្សេងៗទៀតដែរ។ លោកបានចុះផ្សាយនូវអត្ថបទលាតត្រដាង អំពីអំពើពុករលួយប្រព្រឹត្តដោយមន្ត្រីរដ្ឋាភិបាល និងមន្ត្រីយោធាធំៗ ពាក់ព័ន្ធនឹងព្រៃឈើ និងកៅស៊ូក្នុងចំណោមពួកជន ដែលត្រូវបានចោទប្រកាន់ទាំងនោះ ដែលបានចុះ ផ្សាយដោយសារព័ត៌មានមួយឈ្មោះថា ព្រាបនាំសារបាន និយាយថាមានមន្ត្រីយោធា ថ្នាក់វរសេនីយ៍ឯកដ៏ល្បីល្បាញម្នាក់ឈ្មោះ សាត សឿន។ លោក ចាន់ ដារ៉ា ត្រូវបានបាញ់សម្លាប់ក្រោយពីលោកត្រូវបានគេឃើញបានចាកចេញពីភោជនីយដ្ឋានមួយជាមួយ លោក សាត សឿន នៅខេត្តកំពង់ចាម។ នគរបាលក្រសួងមហាផ្ទៃបានចាប់ខ្លួន សាត សឿន ដែលក្រោយមកនៅតែបន្តគំរាមកំហែងដល់សារព័ត៌មានទាំងពីរព្រមទាំងប្រពន្ធរបស់លោក ចាន់ ដារ៉ា។ ក៏ប៉ុន្តែ វរសេនីយ៍ឯកនេះត្រូវបានលើកលែងការចោទប្រកាន់នៅក្នុងសវនាការ ហើយត្រូវបានដោះលែង។

ប៉ុន្មានឆ្នាំក្រោយមកទៀតលោក សាត សឿន បានជាប់ពាក់ព័ន្ធប្រព្រឹត្តបទឧក្រិដ្ឋជាច្រើនទៀត រួមមានការសម្លាប់ និងការកាប់ព្រៃឈើខុសច្បាប់។ បច្ចុប្បន្នលោកស្ថិតនៅក្នុងពន្ធនាគារបន្ទាប់ពីត្រូវបានផ្តន្ទាទោសពីបទប៉ុនប៉ងធ្វើឃាតនៅឆ្នាំ២០០៥។

### **លោក ធន់ ប៊ុនលី** *បាញ់ស្លាប់នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៦*

លោក ធន់ ប៊ុនលី ជាអ្នកនិពន្ធ និងបោះពុម្ពផ្សាយរបស់សារព័ត៌មានប្រឆាំងឈ្មោះថា ឧត្តមគតិខ្មែរ



ហើយក៏ជាសមាជិកគណៈកម្មការនាយកនៃគណបក្សជាតិខ្មែរ (ដែលក្រោយមកក្លាយជាគណបក្ស សម រង្ស៊ី)។ លោកត្រូវបានបាញ់សម្លាប់ពេល ដែលលោកកំពុងជិះម៉ូតូនៅកណ្តាលទីក្រុងភ្នំពេញ។ អ្នកសារព័ត៌មានរូបនេះបានប្តឹងឧទ្ធរណ៍ជំទាស់នឹងការផ្តន្ទាទោសពីបទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិតពីរករណី ដោយបានរិះគន់រដ្ឋាភិបាលនៅក្នុងអត្ថបទ និងរូបតុ្លក។ លោក ធន់ ប៊ុនលី ព្រមទាំងបណ្ណាធិការ នៃសារព័ត៌មានពីរទៀតសុទ្ធតែបានទទួលការព្រមានថា ជីវិតរបស់លោកកំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់។ នៅពេលព្រឹកថ្ងៃដែលលោកស្លាប់ លោកបានចុះផ្សាយនូវអត្ថបទមួយនិយាយថា មានវរសេនីយ៍ត្រី មិនស្គាល់អត្តសញ្ញាណម្នាក់នៅក្នុងកងកម្លាំងសន្តិសុខបានចេញមក និង "សម្លាប់លោក"។ ប្រហែលជាដោយសារអត្ថបទនោះហើយ

មើលទៅ បានជាមានការសម្លាប់លោក ពីព្រោះអត្ថបទនោះបានចំអកឱ្យវរសេនីយ៍ត្រីនោះថាជាមនុស្សស្រវឹង និងគ្មានសមត្ថភាព ។

**លោក ចេត ដួងដារ៉ាវុធ** *ស្លាប់នៅក្នុងការវាយប្រហារដោយគ្រាប់បែកដៃ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧* ។



លោក ដារ៉ាវុធ គឺជាអ្នកយកព័ត៌មាននៃសារព័ត៌មាន អ្នកប្រយុទ្ធ ដែលថ្មីៗនេះបានទទួលការអនុញ្ញាតឱ្យបោះពុម្ពសារព័ត៌មានថ្មី។ លោកក៏ជាសមាជិកគណៈកម្មការនាយកនៃគណបក្សជាតិខ្មែរដែរ។ លោកបានស្លាប់ នៅក្នុងការវាយប្រហារដោយគ្រាប់បែកដៃមួយនៅខាងក្រៅរដ្ឋសភាជាតិនាទីក្រុងភ្នំពេញ ខណៈដែលលោកកំពុងយកព័ត៌មានអំពីការប្រជុំរបស់គណបក្សជាតិខ្មែរ ដែលលោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងកំពុងតែថ្លែងសុន្ទរកថា។ យ៉ាងតិចមានមនុស្ស ១៦ នាក់បានស្លាប់នៅក្នុងការវាយប្រហារនោះ ហើយអ្នកសារព័ត៌មានយ៉ាងតិចណាស់ ២២នាក់ បានរងរបួស និងខ្លះទៀតធ្ងន់ធ្ងរផង។

**លោក ពេជ្រ អែម** *បាញ់នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩៧ ស្លាប់ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៧* ។

លោក ពេជ្រ អែម គឺជាអ្នកបច្ចេកទេស (ហើយតាមរបាយការណ៍ខ្លះ ក៏ជាអ្នកផ្សាយព័ត៌មានផងដែរ) នៅស្ថានីយទូរទស្សន៍ជាតិកម្ពុជា **ធធក** របស់រដ្ឋប្រចាំក្រុងព្រះសីហនុ។ ជាច្រើនថ្ងៃមុននេះ មន្ត្រីនគរបាលជាន់ខ្ពស់ម្នាក់ បានសុំស្នើឱ្យស្ថានីយចាក់ផ្សាយនូវសន្ទរកថានយោបាយរបស់ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច។ ស្ថានីយបានបដិសេធ។ នៅថ្ងៃទី៤ ខែឧសភា មានបុរស ៧ នាក់បានវាយប្រហារស្ថានីយដោយប្រើអាវុធអាកា៤៧ ហើយយ៉ាងតិចក៏មាន បេ ៤០ ពីរដើមដែរ។ លោក ពេជ្រ អែម ត្រូវគេបាញ់ត្រូវពោះចំនួនពីរគ្រាប់ ហើយបានស្លាប់នៅមន្ទីរពេទ្យមួយថ្ងៃក្រោយមក។ មនុស្សពីរនាក់ផ្សេងទៀត ត្រូវបានរងរបួសនៅក្នុងការវាយប្រហារនេះ ហើយឧបករណ៍នៅក្នុងស្ថានីយភាគច្រើនត្រូវខូចខាត។

**លោក ម៉ៃឃីល សុខុន** (ឬ ម៉ៃឃីល ស៊ីនៀ) *ត្រូវគេបាញ់ស្លាប់ក្នុងខែកក្កដា ឆ្នាំ១៩៩៧* ។

លោក សុខុន គឺជាជនជាតិកាណាដា មានដើមកំណើតខ្មែរ ហើយដែលបានវិលត្រឡប់មកកម្ពុជាវិញ ធ្វើការជាអ្នកអានព័ត៌មានទូរទស្សន៍ និងជាគ្រូបង្រៀនភាសាអង់គ្លេស។ លោកត្រូវបានបាញ់ស្លាប់ខណៈដែលលោកកំពុងថតរូបសកម្មភាពលួចឆក់ប្លន់មួយប្រព្រឹត្តដោយពួកយោធានៅក្នុងផ្សារសាធារណៈមួយក្នុងព្រឹត្តការណ៍ឆ្នាំ១៩៩៧។ យោធាមួយក្រុមបានចូលមកជិតលោកហើយឃាត់លោក បន្ទាប់មកបានបាញ់

លោកដំបូងត្រូវចំជង្គង់។ តាមរបាយការណ៍ថា ខណៈដែលលោកដួលនៅលើផ្លូវ លោកបានសុំអង្វរគេកុំឱ្យបាញ់ ពេលនោះគេបានបាញ់លោកម្តងទៀតនៅមុខប្រពន្ធ និងបងថ្លៃរបស់លោក។

**លោក អ៊ូ សារឿន** *បាញ់ស្លាប់នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧* ។

លោក អ៊ូ សារឿន គឺជាអ្នកយកព័ត៌មាននៃសារព័ត៌មាន សម្លេងរាស្ត្រខ្មែរ ហើយជាកូនប្រុសរបស់អ្នកបោះពុម្ពផ្សាយសារព័ត៌មាននោះ។ ពួកសន្តិសុខផ្សារនៅទីក្រុងភ្នំពេញបានអូសលោកមកលើផ្លូវ ហើយបាញ់លោកស្លាប់ទៅ។ ឪពុករបស់លោកបានមានប្រសាសន៍ថា កូនប្រុសរបស់គាត់កំពុងស៊ើបអង្កេតក្នុងរឿងដែលពួកសន្តិសុខជម្រិតទារប្រាក់ពីអ្នកលក់ក្នុងផ្សារ។ របាយការណ៍ផ្លូវការនៃការស្លាប់របស់លោក អ៊ូ សារឿនបាននិយាយថាលោកកំពុងស្រវឹងហើយបានស្លាប់នៅក្នុងជម្លោះក្នុងវង់បៀ ប៉ុន្តែសមាគមអ្នកសារព័ត៌មានខ្មែរនៅតែអះអាងថា លោកត្រូវបានគេសម្លាប់ដោយសារតែការយកព័ត៌មានសំរាប់សារព័ត៌មាន។ នគរបាលបានចាប់ខ្លួនកងសន្តិសុខដែលបានបាញ់លោក អ៊ូ សារឿន ប៉ុន្តែក្រោយមកគេបានដោះលែងវិញ ហើយគ្មានការចោទប្រកាន់ទៅលើជនមុខសញ្ញានោះទៀតឡើយ។

**លោក ជូ ជេដ្ឋារិទ្ធ** *បាញ់ស្លាប់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៣* ។

លោក ជេដ្ឋារិទ្ធ គឺជាបណ្ណាធិការរងនៃស្ថានីយវិទ្យុតាព្រហ្ម ដែលជាវិទ្យុមានសម្ព័ន្ធភាពជាមួយគណបក្សហ៊្វុនស៊ិនប៉ិច។ មនុស្សពីរនាក់ជិះម៉ូតូមួយគ្រឿងបានបាញ់លោកស្លាប់នៅមុខការិយាល័យរបស់លោកទាំងថ្ងៃ។ បួនថ្ងៃមុននេះ រដ្ឋាភិបាលបានចោទប្រកាន់វិទ្យុតាព្រហ្មថា បានប្រមាថមើលងាយការដឹកនាំរបស់រដ្ឋាភិបាល ហើយបានព្រមានស្ថានីយថា "ត្រូវតែត្រួតពិនិត្យកម្មវិធីរបស់ខ្លួនឡើងវិញ" ប្រសើរជាង។



ឃាតកម្មលើរូបលោក ជេដ្ឋារិទ្ធ កើតឡើងនៅមុនពេលការពិភាក្សាដែលបានគ្រោងទុករវាងភាគីទាំង៣ គឺគណបក្សប្រជាជនកម្ពុជា ហ៊្វុនស៊ិនប៉ិច និងសម រង្ស៊ី ដើម្បីបញ្ចប់នូវបញ្ហានយោបាយ ក្រោយពីគណបក្សប្រជាជនកម្ពុជាពុំមានទទួលសម្លេងគាំទ្រភាគច្រើន ពីរភាគបី នៅក្នុងការបោះឆ្នោតជាតិឆ្នាំ ២០០៣។ ការពិភាក្សានោះត្រូវបានលប់ចោលវិញ ក្រោយពីមានឃាតកម្មលើអ្នកសារព័ត៌មាន។ ប៉ុន្មានខែក្រោយមកគណបក្សហ៊្វុនស៊ិនប៉ិច បានយល់ព្រមចូលរួមក្នុងរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជាជនកម្ពុជាជាថ្មីម្តងទៀត។

ក្រោយពីមានអំពើឃាតកម្មរួចហើយ លោក ហេង ពៅ ដែលជាស្នងការនគរបាលរាជធានីភ្នំពេញកាលពីសម័យនោះ បានមានប្រសាសន៍ថា នគរបាលបានកំណត់អត្តសញ្ញាណជនសង្ស័យរួចហើយ ប៉ុន្តែពុំទាន់មានភស្តុតាងគ្រប់គ្រាន់ដើម្បីចាប់ជនណាមួយបាននៅឡើយទេ។

**លោក ឃឹម សំបូរ :** *ត្រូវគេបាញ់សម្លាប់នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨*

លោក ឃឹម សំបូរ គឺជាអ្នកសារព័ត៌មានជំទាស់ម្នាក់ បម្រើការងារនៅសារព័ត៌មានមនសិការខ្មែរ លោកត្រូវបានមនុស្សពីរនាក់កាន់កាំភ្លើងបាញ់សម្លាប់ ដោយជិះលើទោចក្រយានយន្តមួយគ្រឿង ហើយបាញ់ត្រូវ៣គ្រាប់នៅកណ្តាលវាំល។ នៅក្នុងព្រឹត្តិការណ៍នោះ កូនប្រុសរបស់លោកឈ្មោះ ខាត់ សារិន ដែលរួមដំណើរជាមួយគ្នាក្នុងពេលនោះ ក៏ត្រូវឃាតករបាញ់សម្លាប់ផងដែរ។



លោក សំបូរ ច្រើនតែសរសេរអត្ថបទដាក់ឈ្មោះថា សរសេរដោយ "*ស្រីកា ឬ ដែនសុរិន្ទ*" ដែលជាអត្ថបទរិះគន់គណបក្សកាន់អំណាចក្នុងរដ្ឋាភិបាល និងមន្ត្រីជាន់ខ្ពស់មួយចំនួន។ ឃាតកម្មនេះកើតឡើងតែ ២សប្តាហ៍មុនពេលបោះឆ្នោតជាតិតែប៉ុណ្ណោះ។ មន្ត្រីនគរបាលកម្ពុជាមិនទាន់រកឃើញមូលហេតុ ឬជនសង្ស័យក្នុងករណីឃាតកម្មនោះឡើយ។

□□□

# តារាងការគំរាមកំហែង និងវាយប្រហារលើប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មានៈ ខែមករា ឆ្នាំ២០០៨ ដល់ ខែមីនា ឆ្នាំ២០០៩

| កាលបរិច្ឆេទ | ករណីពិស្តារ |
|---|---|
| *ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨* | **អ្នកសារព័ត៌មានលាក់ខ្លួនក្រោយពីចេញដីកាចាប់ខ្លួន** [៨]<br>▪ *អ្នកសារព័ត៌មានមកពីសារព័ត៌មានភាសាខ្មែរចំនួន ៣ នាក់ ដែលមិនសូវគេស្គាល់បានភៀសខ្លួនពីខេត្តពោធិ៍សាត់ ក្រោយពីតុលាការបានចេញដីកាចាប់ខ្លួន ដោយចោទប្រកាន់ពីបទបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ។*<br>▪ *មេបញ្ជាការរងកងអាវុធហត្ថខេត្ត ឈ្មោះ ស៊ុម សាប់ បាននិយាយថា នៅថ្ងៃទី១៥ ខែមករា បុរសទាំង ៣ នាក់ នោះ បានដាក់ប៉ុស្តិ៍ត្រួតពិនិត្យមួយនៅថ្ងៃទី៨ ខែមករា បណ្តាលឱ្យរថយន្តដឹកត្រីមួយគ្រឿងក្រឡាប់ ហើយអ្នកបើកបរបានរងរបួស ។*<br>▪ *ប៉ុន្តែ អ្នកសារព័ត៌មានម្នាក់ ឈ្មោះ ប្រាក់ សុខុន អាយុ ៣២ ឆ្នាំ បាននិយាយតាមទូរស័ព្ទថា ពួកគេគ្រាន់តែបានចតរថយន្តរបស់ខ្លួននៅជិតស្ពានមួយ ដើម្បីថតរូបស៊ើបអង្កេតការដឹកជញ្ជូនត្រីគេចពន្ធតែប៉ុណ្ណោះ ។* |
| *ថ្ងៃទី១៨ ខែមករា* | **តុលាការសួរចម្លើយបណ្ណាធិការសារព័ត៌មានអំពីអត្ថបទ" បទបរិហាកេរ្តិ៍"** [៩]<br>▪ *នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨ អ្នកបោះពុម្ពផ្សាយសារព័ត៌មានជំទាស់ បាននិយាយថា តុលាការក្រុងភ្នំពេញ បានសួរចម្លើយលោកពាក់ព័ន្ធនឹងបណ្តឹងបរិហារកេរ្តិ៍ប្តឹងដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មឯ.ឧ ចម ប្រសិទ្ធ ។*<br>▪ *លោក ហង្ស ចក្រា អ្នកសារព័ត៌មានខ្មែរម្ចាស់ស្រុក ដែលគេមិនសូវស្គាល់ បាននិយាយថា គាត់ត្រូវបានតុលាការសួរចម្លើយនៅថ្ងៃទី១៥ ខែមករា អំពីអត្ថបទចោទប្រកាន់ ឯ.ឧ ចម ប្រសិទ្ធ និងលោកជំទាវ ដែលត្រូវបានចុះផ្សាយក្នុងទំព័រសារព័ត៌មានរបស់លោកកាលពីខែកញ្ញា និងខែតុលា ឆ្នាំ២០០៧ ។*<br>▪ *សារព័ត៌មាននេះ បច្ចុប្បន្នមិនចេញផ្សាយទៀតទេ ។* |

[៨] សាំង សុឥន្ទរិទ្ធ-ឌី ឃែមបូឌា ដេលី: *អ្នកសារព័ត៌មានលាក់ខ្លួន ក្រោយពីចេញដីកាចាប់ខ្លួន* ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨។

[៩] ប្រាក់ ចន្ទុល-ឌី ឃែមបូឌា ដេលី: *តុលាការសួរចម្លើយអំពីអត្ថបទរិះគន់* ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ។

***ថ្ងៃទី២០ ខែមករា***

**កងរាជអាវុធហត្ថប្ដឹងអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី និងក្រុមសិទ្ធិមនុស្ស**[១០]

- *តុលាការខេត្តស្ទឹងត្រែង បានចោទប្រកាន់អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរីឈ្មោះ រដ្ឋា វិសាល និងសកម្មជនសិទ្ធិមនុស្ស អាដហុក ឈ្មោះ ឆាយ រ័ត្ន ពីបទផ្សាយព័ត៌មានមិនពិត និងការស៊ើបអង្កេតមិនត្រឹមត្រូវ ។*
- *តាមរបាយការណ៍ថា ការចាប់ខ្លួនត្រូវបានធ្វើឡើងពេលកងរាជអាវុធហត្ថស្រុកម្នាក់បានបង្ខំកុមារីម្នាក់ឱ្យរៀបការជាមួយខ្លួន និងបានវាយដំឪពុកកុមារីនោះ ។*
- *មន្ត្រីកងរាជអាវុធហត្ថស្រុកសៀមបូកម្នាក់ ឈ្មោះ ជា សំណាង បានប្ដឹងអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី និងទារជម្ងឺចិត្ត ១០ លាន រៀល ជាថ្នូរនឹងការខូចឈ្មោះដោយបទបរិហាកេរ្តិ៍នោះ ។ លោកក៏បានសំណូមពរឱ្យតុលាការចោទប្រកាន់ ឈ្មោះ ឆាយ រ័ត្ន ពីបទស៊ើបអង្កេតក្រៅផ្លូវច្បាប់ផងដែរ ។*
- *តុលាការមិនទាន់បានចាត់ការចំពោះករណីបុរសទាំងពីរនាក់នេះទេ ហើយករណីនេះ គឺកំពុងមិនទាន់សំរេចនៅឡើយ ។*

***ថ្ងៃទី២៩ ខែមករា***

**នគរបាលសួរចម្លើយអ្នកសារព័ត៌មាន អំពីការឃុំឃាំងកាលពីខែធ្នូ**[១១]

- *នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ អ្នកយកព័ត៌មានវិទ្យុសម្លេងប្រជាធិបតេយ្យឈ្មោះ សូ វិសាល ត្រូវបានសួរចម្លើយដោយក្រសួងមហាផ្ទៃអំពីបញ្ហាកើតឡើងកាលពី ខែធ្នូ ដែលនគរបាលបានឃុំខ្លួនលោកនៅពេលលោកយកព័ត៌មានអំពីការរុះរើរូបបដិមាករព្រះពុទ្ធមួយអង្គយ៉ាងធំ ។*
- *លោក សូ វិសាល បានអះអាងថា មន្ត្រីនគរបាលឃុំខ្លួនលោកអស់រយៈពេលជិត ១ ម៉ោងនៅថ្ងៃទី២៤ ខែធ្នូ ហើយបានលប់រូបភាពក្នុងម៉ាស៊ីនថតរូបរបស់លោកចោលទាំងអស់ ពេលលោកថតបានរូបភាពកំពុងរុះរើបំផ្លាញរូបបដិមាករនៅវត្តនិរោធរង្សី ក្នុងខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។*
- *រូបបដិមាករព្រះពុទ្ធនោះត្រូវបានរុះរើចេញ ពីព្រោះវាប៉ះពាល់ដល់ការកសាងផ្លូវ ។*

---

[១០] សារព័ត៌មានរស្មីកម្ពុជា: *កងរាជអាវុធហត្ថប្ដឹងអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី និងក្រុមសកម្មជនសិទ្ធិមនុស្ស* ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ ។

[១១] ឌី ឃែមបូឌា ដេលី: *នគរបាលបានសួរចម្លើយអ្នកសារព័ត៌មានអំពីការឃុំឃាំងកាលពីខែធ្នូ* ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ។

ថ្ងៃទី៣០ ខែមករា

- *លោក សូ វិសាល បានទទួលព័ត៌មានថា មានកម្មករម្នាក់បានស្លាប់នៅកន្លែងរុះរើបំផ្លាញរូបបដិមាករព្រះពុទ្ធនោះ ហើយបានទៅសាកសួរយកព័ត៌មាននៅទីនោះ ។ ក្រោយមក ពុំមានការអះអាងអំពីការស្លាប់នោះទេ ។*
- *មន្ត្រីនគរបាលម្នាក់មកពីក្រសួងមហាផ្ទៃ ក្រោយមកបានសុំទោស លោក សូ វិសាល អំពីបញ្ហាការឃុំឃាំងខ្លួនលោកនោះ ។*

**រដ្ឋាភិបាលបានបង្កើត "ក្រុមឆ្លើយតបភ្លាមៗ"** [១២]

- *រដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមពិសេសមួយហៅថា "ក្រុមឆ្លើយតបភ្លាមៗ" សម្រាប់តតាំងជាមួយប្រព័ន្ធផ្សាយព័ត៌មានជំទាស់ និងស្ថានីយវិទ្យុបរទេសនានា ដែលផ្សាយព័ត៌មានវាយប្រហាររដ្ឋាភិបាល ។*
- *នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ ក្រសួងព័ត៌មានបានចេញសេចក្តីណែនាំដែលមាន ៦ ចំណុចទប់ស្កាត់កុំឱ្យបណ្ណាធិការសារព័ត៌មាន និងទស្សនាវដ្តីនានា សរសេររិះគន់ព្រះមហាក្សត្រ សន្តិសុខ ឬសណ្តាប់ធ្នាប់សង្គម ។ មិនត្រូវប្រើប្រាស់ពាក្យពេចន៍អសុរស ឬ ប្រើពាក្យពេចន៍ចំអកមើលងាយ ឬ ប្រើប្រាស់រូបភាពសត្វពេលពិពណ៌នាអំពីសាសនា ឬ ស្ថាប័ននានាដូចជា ព្រឹទ្ធសភា រដ្ឋសភា ឬ រដ្ឋាភិបាល ជាដើម ។*
- *"ក្រុមឆ្លើយតបភ្លាមៗ" នេះ នៅតែមិនទាន់រំសាយនៅឡើយទេ ក៏ប៉ុន្តែមិនសូវមានសកម្មភាព ។*

ថ្ងៃទី១ ខែកុម្ភៈ

**ក្រសួងបានចេញបញ្ជាឱ្យធ្វើការកែទម្រង់ ស្ថានីយវិទ្យុហ៊្វុនស៊ីនប៉ិច** [១៣]

- *ក្រសួងព័ត៌មានបានបញ្ជាឱ្យស្ថានីយវិទ្យុតាព្រហ្ម ដែលគាំទ្រគណបក្សហ៊្វុនស៊ីនប៉ិច ឱ្យធ្វើការណែនាំអ្នកអានព័ត៌មានរបស់ខ្លួន ឱ្យឈប់បញ្ចេញបញ្ចូលពាក្យសម្តីពេលអានអត្ថបទសារព័ត៌មានភាសាខ្មែរ ។*
- *លោក វណ្ណ ឆៃ ជាផលិតករកម្មវិធីវិទ្យុតាព្រហ្ម បាននិយាយថា ក្រោយមកស្ថានីយវិទ្យុនេះបានប្រាប់អ្នកអានព័ត៌មានរបស់ខ្លួនឱ្យឈប់ពោលពាក្យបន្ថែម ហើយបញ្ហានេះគេបានស្តីបន្ទោសដាក់កំហុសទៅលើអ្នកអានព័ត៌មាននោះ ។*

---

[១២] សុខ សេរី-វិទ្យុអាស៊ីសេរី: *សម្តេចនាយករដ្ឋមន្ត្រី បង្កើត "ក្រុមឆ្លើយតបភ្លាមៗ"* ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨។ សូមស្វែងរកផងដែរ: http://ki-media.blogspot.com/2008/01/hun-sens-govt-set-up-quick-response.html ។

[១៣] ប្រាក់ ចន្ទុល- ឌី ឃែមបូឌា ដេលី: *ក្រសួងបានបញ្ជាឱ្យធ្វើការកែទម្រង់វិទ្យុហ៊្វុនស៊ីនប៉ិច* ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨។

- *មកដល់ពេលនេះ អ្នកអានព័ត៌មានទាំងនោះបានអនុវត្តតាមការណែនាំរបស់ក្រសួង។ កម្មវិធីដែលមានបញ្ហានោះ គឺនៅតែបន្តអនុវត្តនៅឡើយ ប៉ុន្តែអ្នកអានព័ត៌មានមិនអាចពោលថែមថយបានដូចមុនៗទៀតឡើយ ចំពោះអត្ថបទដែលបានអាននោះ។*

**ថ្ងៃទី១ ខែមីនា**

**សាលាក្រុងបានហាមចម្រៀងមួយចំនួន ដោយនិយាយថា ប៉ះពាល់ដល់សីលធម៌**[១៤]

- *សាលាក្រុងភ្នំពេញ បានអនុវត្តនូវការហាមឃាត់បទចម្រៀងដែលមានប្រជាប្រិយមួយចំនួន ដោយអះអាងថា ពាក្យពេចន៍មនោសញ្ចេតនាពេក បានធ្វើឱ្យមានការប៉ះពាល់ដល់សីលធម៌អាពាហ៍ពិពាហ៍ ។*
- *លោក មុំ សុទ្ធ នាយកមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈបានមានប្រសាសន៍ថា មានការហាមឃាត់ចំពោះបទចម្រៀងខុសច្បាប់មួយចំនួនរួមទាំង "ហាមមិនឱ្យលក់ និងចាក់ផ្សាយតាមទីសាធារណៈនានា"។ លោកមុំ សុទ្ធ បានប្រសាសន៍ បន្ថែមទៀតថា ការហាមប្រាមនោះបានចូលជាធរមានក្រោយពីភិរិយាសម្តេចនាយករដ្ឋមន្ត្រីបានរិះគន់ចំពោះពាក្យពេចន៍មិនសមរម្យដែលមាននៅក្នុងបទចម្រៀងប្រជាប្រិយមួយចំនួន កាលពីខែមករា ឆ្នាំ២០០៨ កន្លងទៅ។*

**ថ្ងៃទី១៨ ខែមីនា**

**សារព័ត៌មានស្រឡាញ់ខ្មែរបានដូរទិសដៅ**[១៥]

- *នៅថ្ងៃទី១៣ ខែមីនា បណ្ណាធិការនៃសារព័ត៌មានស្រឡាញ់ខ្មែរ ជាសារព័ត៌មានជំទាស់ឈ្មោះ ថាច់ កេត អាយុ ៥៣ ឆ្នាំ ដែលជាសមាជិក គណកម្មាធិការនាយករបស់ គណបក្ស សម រង្ស៊ី ត្រូវបានរាយការណ៍ថា បានដាក់សំណើទៅគណបក្ស សម រង្ស៊ី សុំផ្តាច់ខ្លួន ដើម្បីចូលរួមគាំទ្រគណបក្សប្រជាជនកម្ពុជាវិញ។*
- *ក្រោយមកអគ្គនិពន្ធនាយកនៃសារព័ត៌មាននេះ ឈ្មោះ ប៊ុយ វឿយ បានមានប្រសាសន៍ថា រោងពុម្ពអង្គរបានឈប់បោះពុម្ពសារព័ត៌មាននេះតទៅទៀតហើយ ដោយអះអាងថា មានមនុស្សពីក្រសួងព័ត៌មានបានណែនាំឱ្យធ្វើបែបនេះ។*

---

[១៤] ឌី ឃៃមបូឌា ដេលី: *សាលាក្រុងហាមបទចម្រៀង ដោយបាននិយាយថា ធ្វើឱ្យប៉ះពាល់ដល់សីលធម៌* ថ្ងៃទី១ ខែមីនា ឆ្នាំ២០០៨

[១៥] យន់ សាមៀន-ឌី ឃៃមបូឌា ដេលី: *អ្នកបោះពុម្ពផ្សាយសារព័ត៌មានស្រឡាញ់ខ្មែរបានបញ្ជាក់អំពីការគាំទ្រគណបក្សប្រជាជនកម្ពុជា* ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៨។ សូមអានអត្ថបទសារព័ត៌មានរស្មីកម្ពុជាផងដែរ ដែលមានចំណងជើងថា *កាសែតស្រឡាញ់ខ្មែរបានដូរទិស* ថ្ងៃទី១៨ មីនា ២០០៨។ របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ។

ថ្ងៃទី១០ ខែមេសា

- សារព័ត៌មានរស្មីកម្ពុជាបានរាយការណ៍ថា លោក ថាច់ កេត បានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ហើយទូរទស្សន៍ ស៊ី ធី អិន ក៏បានផ្សព្វផ្សាយព័ត៌មាននេះដែរ ។ ពេលធ្វើការផ្សាយនោះ លោក ថាច់ កេត កំពុងស្ថិតនៅប្រទេសវៀតណាម ហើយបានទូរស័ព្ទមកសហការីរបស់លោកឱ្យបដិសេធអត្ថបទផ្សាយនោះ ។ គណបក្ស សម រង្ស៊ី ក៏បានបដិសេធថាគាត់មិនបានចាកចេញពីគណបក្សរបស់ខ្លួនដែរ ។
- ក្រោយមកលោក ថាច់ កេត បានមានប្រសាសន៍ថា លោកបានផ្លាស់ប្តូរគោលការណ៍របស់សារ-ព័ត៌មានដោយឈប់រិះគន់រដ្ឋាភិបាលទៀត ហើយបានប្តូរសម្ព័ន្ធភាពនយោបាយរបស់សារព័ត៌មានដែរ ។
- កាលពីមុនលោក ថាច់ កេត បានទទួលរងការគំរាមកំហែង និងបំភិតបំភ័យ ។ នៅយប់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៧ មនុស្សមិនស្គាល់អត្តសញ្ញាណបានព្យាយាមកៀ លោកទម្លាក់ផ្លូវ បន្ទាប់ពីលោកចាកចេញពីកន្លែងធ្វើការ ត្រឡប់ទៅផ្ទះវិញ ។ ឆ្នាំមុននេះលោកបានរាយការណ៍ថា លោក ហ៊ុន តូ បានគំរាមកំហែងដល់អាយុជីវិតរបស់លោក ក្រោយពីលោកបានចេញផ្សាយអត្ថបទអំពីទំនាស់ដីធ្លី និង អំពើពុករលួយនៅខេត្តរតនគិរី ។
- នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ សារព័ត៌មានស្រឡាញ់ខ្មែរ បានឈប់បោះពុម្ពផ្សាយ ដោយសារបញ្ហាខ្វះខាតថវិកា និងចំនួនអ្នកអាន បានថយចុះ ។

### អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរីត្រូវបានទទួលការគំរាមកំហែងដល់អាយុជីវិត [១៦]

- នៅថ្ងៃទី ១០ ខែមេសា ឆ្នាំ២០០៨ លោក លឹម ពិសិដ្ឋ អ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី ត្រូវបានគេគំរាមកំហែងដល់អាយុជីវិត ។ លោកបាននិយាយថា មានគេទម្លាក់គ្រាប់កាំភ្លើងអាកា ៤៧ ចំនួន ៦ គ្រាប់នៅខាងក្រៅផ្ទះរបស់លោក នៅខេត្តបាត់ដំបង ។
- ៣ ថ្ងៃក្រោយមកនៅភ្នំពេញ ម៉ោង ៦ ល្ងាច មនុស្សមួយក្រុមមានគ្នា ៨ នាក់ ជិះទោចក្រយានយន្តបានតាមលោក លឹម ពិសិដ្ឋ ពេលកំពុងជិះតាមផ្លូវស្ងាត់មួយ ។

[១៦] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ: សូមមើល http://www.licadho-cambodia.org/articles/20080508/74/index.html; http://www.rsf.org/article.php3?id_article=22609 សូមមើលផងដែរ: http://www.fidh.org/KHM-003-0607-OBS-068-Death-threats សូមមើលផងដែរ: http://www.freemedia.at/cms/ipi/freedom_detail.html?country=/KW0001/KW0005/KW0113/&year=2007

ថ្ងៃទី២២ ខែឧសភា

- *កាលពីមុន លោក លឹម ពិសិដ្ឋ បានទទួលការគំរាមកំហែងដល់អាយុជីវិត ដោយលោកបានផ្សាយអត្ថបទដែលជាចំនុចរសើបអំពីអ្វីដែលលោកបានស៊ើបអង្កេត និងរាយការណ៍ ។*
- *នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ មនុស្សមិនស្គាល់អត្តសញ្ញាណម្នាក់បានផ្ញើសារតាមទូរស័ព្ទដៃអញ្ជើញលោកទៅជួបនៅភោជនីយដ្ឋាន ឆាយ៉ា ។ លោក លឹម ពិសិដ្ឋ បានទូរស័ព្ទទៅលេខនោះវិញ ប៉ុន្តែគ្មានអ្នកណាលើកទូរស័ព្ទនោះទេ ។*
- *លោក លឹម ពិសិដ្ឋ បានស៊ើបអង្កេតយ៉ាងសកម្មអំពីករណីជួញដូរឈើខុសច្បាប់ធំៗ នៅឃុំ ទំរីង និងព្រៃឡង់ ខេត្តកំពង់ធំ ។*
- *នៅ ខែឧសភា ឆ្នាំ២០០៨ លោក លឹម ពិសិដ្ឋ និងគ្រួសាររបស់លោកបានសុំសិទ្ធិជ្រកកោណនយោបាយនៅប្រទេសថៃ ដោយមានការគាំទ្រពីភ្នាក់ងារអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ។*
- *នៅខែមករា ឆ្នាំ២០០៩ លោក លឹម ពិសិដ្ឋ និងគ្រួសាររបស់លោក បានទទួលសិទ្ធិជ្រកកោណនៅប្រទេស ន័រវេ ។*

**សម្តេចនាយរដ្ឋមន្ត្រីៈ ឥទ្ធិពលប្រព័ន្ធផ្សាយព័ត៌មានផ្តល់គុណសម្បត្តិដល់គណបក្សប្រជាជនកម្ពុជា** [១៧]

- *សម្តេចនាយករដ្ឋមន្ត្រី បានរិះគន់កម្មវិធីជំទាស់របស់វិទ្យុសម្បុកឃ្មុំ ដោយមានប្រសាសន៍ថា សម្តេចនឹងប្រើប្រាស់ធនធានប្រព័ន្ធផ្សាយព័ត៌មានដ៏ខ្លាំងរបស់សម្តេច ដើម្បីលប់សម្លេងរិះគន់កុំឱ្យឮ ។ សម្តេចមានប្រសាសន៍ថា "អ្នកមានស្ថានីយវិទ្យុតែមួយ ចំណែកខ្ញុំមាន ៣៩" និងបន្ថែមទៀតថា "អ្នកដែលរិះគន់ខ្ញុំកាលពីមុនៗ ឥឡូវបាត់ពីពិភពគុណអស់ហើយ" ។*
- *គណបក្ស សម រង្ស៊ី នរោត្តម រណឫទ្ធិ និងគណបក្សសិទ្ធិមនុស្ស សុទ្ធតែបានជួលម៉ោងផ្សាយពីវិទ្យុសម្បុកឃ្មុំ ១ ម៉ោង ម្នាក់ចន្លោះពីម៉ោង ១១ ទៅម៉ោង ១ រសៀល ។ គណបក្សទាំង ៣ នេះគ្មានគណបក្សណាមួយមានស្ថានីយវិទ្យុ ឬ ទូរទស្សន៍គាំទ្រខ្លួនផ្ទាល់ទេ ។*
- *មេធាវី គណបក្ស សម រង្ស៊ី លោក យឹម សុវណ្ណ បានមានប្រសាសន៍ថា កំណត់សំគាល់របស់សម្តេចនាយក គឺចង់បំភិតបំភ័យអ្នកបោះឆ្នោត និងគំរាមដល់សេរីភាពក្នុងការបញ្ចេញមតិ ។*

---

[១៧] ឌី យៃមបូឌា ដេលីៈ *នាយករដ្ឋមន្ត្រីៈ ឥទ្ធិពលប្រព័ន្ធផ្សាយព័ត៌មានផ្តល់គុណសម្បត្តិឱ្យគណបក្សប្រជាជនកម្ពុជា* ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨

ថ្ងៃទី២៨ ខែមករា

**ស្ថានីយវិទ្យុខេត្តក្រចេះត្រូវបានបិទក្រោមការចោទប្រកាន់ពីបទរំលោភកិច្ចសន្យា**[១៨]

- *ស្ថានីយវិទ្យុអង្គរវដ្ដា ត្រូវបានបិទដោយរដ្ឋមន្ដ្រីក្រសួងព័ត៌មាន ឯ.ឧ. ខៀវ កាញារីទ្ធ ដោយចោទប្រកាន់ថាបានរំលោភកិច្ចសន្យាផ្សាយរបស់ខ្លួន ។*
- *ស្ថានីយនោះត្រូវបានបិទក្រោយពីធ្វើការផ្សាយបានតែ ១៣ ថ្ងៃ ប៉ុណ្ណោះ ។ ស្ថានីយនេះបានទទួលអាជ្ញាប័ណ្ណនៅខែមករា ហើយក៏បានជួលម៉ោងផ្សាយរបស់ខ្លួនឱ្យគណបក្សនយោបាយ និងអង្គការនានាជាច្រើនដូចជាគណបក្ស សម រង្ស៊ី ហ្វ៊ុនស៊ីនប៉ិច នរោត្ដម រណឫទ្ធិ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងកម្មវិធីវិទ្យុសម្លេងប្រជាធិបតេយ្យ ជាដើម ។*
- *រថយន្ដពីរគ្រឿងដឹកនគរបាល និងកងរាជអាវុធហត្ថស្រុកបានមកដល់ស្ថានីយ ហើយបានអានបទបញ្ជាបិទ ។ ពុំមានការពន្យល់ ឬ មូលហេតុណាមួយបញ្ជាក់នៅក្នុងបទបញ្ជាបិទស្ថានីយវិទ្យុនោះឡើយ ។*
- *នៅវេលាម៉ោង ៣ រសៀលថ្ងៃនោះ នាយកមន្ទីរព័ត៌មានខេត្តក្រចេះ ឈ្មោះ ណៃ ធីតា បានទូរស័ព្ទហៅនាយករងស្ថានីយវិទ្យុ ឈ្មោះ ឃីម សុមាលី ហើយបានសួរថា តើស្ថានីយនេះ បានជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយណាដែរ ឬទេ ។*
- *លោក កែវ ច័ន្ទវដ្ដា អគ្គនាយក ស្ថានីយវិទ្យុអង្គរវដ្ដាបានមានប្រសាសន៍ថា ការបិទត្រូវបានធ្វើឡើងដោយគ្មានការជូនដំណឹងទេ ។ លោកបានព្យាយាមចចារជាមួយក្រសួងព័ត៌មាន ហើយក្រោយមក ស្ថានីយនេះត្រូវបានអនុញ្ញាត ឱ្យបើកឡើងវិញដោយត្រូវប្ដូរឈ្មោះថ្មី ។*
- *ទោះបីជាក្រសួងព័ត៌មាន អនុញ្ញាតឱ្យគណបក្សនយោបាយធ្វើការផ្សាយសម្លេង ស្រដៀងគ្នានេះតាមស្ថានីយមួយចំនួនដូចជា សម្បុកឃ្មុំនៅភ្នំពេញ និង អង្គរវដ្ដា នៅខេត្តសៀមរាបក៏ដោយក៏ក្រសួងព័ត៌មានបានដកអាជ្ញាប័ណ្ណរបស់ស្ថានីយ ខេត្តក្រចេះនេះភ្លាមៗ ។*
- *ស្ថានីយវិទ្យុនេះនៅតែបិទដដែល ។*

[១៨] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ ។ សូមមើល: http://www.ifex.org/en/content/view/full/94379

**ថ្ងៃទី៩ ខែមិថុនា**

**អគ្គនិពន្ធនាយកត្រូវបានឃុំខ្លួនពីបទបរិហារកេរ្តិ៍**[១៩]

- *នៅថ្ងៃទី៨ ខែមិថុនា អគ្គនិពន្ធនាយកនៃសារព័ត៌មានគាំទ្រគណបក្ស សម រង្ស៊ី មនសិការខ្មែរ ឈ្មោះ ដាំ សិទ្ធិ ត្រូវបានចាប់ និងឃុំខ្លួនដោយតុលាការក្រុងភ្នំពេញ ក្រោមការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ជេរប្រមាថ និងផ្សាយព័ត៌មានមិនពិត ។*
- *ការចាប់ខ្លួនរបស់លោកក៏ត្រូវបានធ្វើឡើង ក្រោយពីមានអត្ថបទមួយចេញផ្សាយ នៅថ្ងៃទី១៨ ខែមេសា ដែលបានដកស្រង់សម្តីរបស់លោក សម រង្ស៊ី ចោទប្រកាន់ ឯ.ឧ. ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេសថា មានការជាប់ពាក់ព័ន្ធជាមួយខ្មែរក្រហម ។*
- *គេបាននាំខ្លួនលោក ដាំ សិទ្ធិ ទៅក្នុងបន្ទប់មួយបិទជិតនៅតុលាការក្រុងភ្នំពេញវេលាម៉ោង ៣ រសៀល ហើយក្រោយមកត្រូវបញ្ជូនទៅពន្ធនាគារព្រៃស នៅវេលាប្រហែលម៉ោង ៥.៣០ ល្ងាច ។ ជាធម្មតាតុលាការក្រុងបិទនៅថ្ងៃអាទិត្យ ដែលថ្ងៃទី៨ ខែមិថុនា នោះគឺជាថ្ងៃអាទិត្យ ។*
- *នៅថ្ងៃទី១៥ ខែមិថុនា គេបានដោះលែងលោក ដាំ សិទ្ធិ ឱ្យនៅក្រៅឃុំបណ្តោះអាសន្នក្រោមបញ្ជារបស់តុលាការក្រុង*[២០] *ក្រោយពីមានបញ្ជាពីសម្តេចនាយករដ្ឋមន្ត្រី ។*
- *លោកចៅក្រម ឆាយ គង់ បានបញ្ជាក់ថា លោកបានបញ្ជាឱ្យដោះលែងលោក ដាំ សិទ្ធិ ដោយបន្ថែមថា គាត់នឹងបន្តស៊ើបអង្កេតករណីនេះតទៅទៀត ។*

**ថ្ងៃទី២៧ ខែមិថុនា**

**អ្នកសារព័ត៌មានត្រូវគ្រាប់ចំពាមក្នុងពេលយកព័ត៌មានអំពីការកាប់ឈើខុសច្បាប់នៅកំពង់ធំ**[២១]

- *នៅថ្ងៃទី២៧ អ្នកសារព័ត៌មានម្នាក់បានរងរបួសយ៉ាងខ្លាំងពីការបាញ់ចំពាម ដោយបុរសម្នាក់ដែលពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់ ។ ការបាញ់ចំពាមនេះ កើតឡើងពេលដែលលោកកំពុងជិះទោចក្រយានយន្តពីភូមិរលាទង ទៅឃុំក្រយា ក្នុងស្រុកសន្ទុក (ចម្ងាយប្រហែល ១០០ ម៉ែត្រពីការដ្ឋានកាប់ឈើខុសច្បាប់)*

---

[១៩] យន់ សាមៀន និងកាទី នេលសុន- ឌី ឃែមបូឌា ដេលី: *អគ្គនិពន្ធនាយកត្រូវបានចាប់ខ្លួនពីបទបរិហារកេរ្តិ៍* ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨។ សូមមើលផងដែរ: http://www.licadho-cambodia.org/press/files/184JointPRArrestDamSithNewspaperEditor08.pdf សូមមើលផងដែរ: សារព័ត៌មានរស្មីកម្ពុជា: *អគ្គនិពន្ធនាយកនៃសារព័ត៌មានមនសិការខ្មែរត្រូវបានឃុំខ្លួនពីបទបរិហាកេរ្តិ៍* ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨។ យន់ សាមៀន-ឌី ឃែមបូឌា ដេលី: *ក្រុមសិទ្ធិមនុស្សអំពាវនាវឱ្យដោះលែងអគ្គនិពន្ធនាយក* ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨។

[20] យន់ សាមៀន: ឃែមបូឌាដេលី: និពន្ធនាយក ដាំ សិទ្ធិ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ។

[២១] សារព័ត៌មានកម្ពុជាថ្មី: *អ្នកយកព័ត៌មាននៅកំពង់ធំត្រូវគ្រាប់ចំពាមរបស់ឈ្មួញកាប់ឈើខុសច្បាប់* ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៨។

- *អ្នកសារព័ត៌មានម្នាក់ទៀតនិយាយថា លោក និងលោក រី នៅ អាយុ៤០ឆ្នាំ ជាអ្នកសារព័ត៌មាន នៃសារព័ត៌មានមាតុភូមិ កំពុងស៊ើបអង្កេតក្នុងករណីកាប់ឈើខុសច្បាប់ ។ មនុស្សមួយក្រុមបាញ់លោកដោយចំពាមកៅស៊ូ ត្រូវចំមុខរបួសយ៉ាងធ្ងន់ ។ ការបាញ់នេះ ធ្វើឱ្យទោចក្រយានយន្តរបស់លោកដួល ហើយលោកបានសន្លប់មួយសន្ទុះ ។ ពួកជនបាញ់ចំពាមទាំងនោះបានរត់គេចខ្លួនពេលដែលលោកបានស្រែកឱ្យអ្នកភូមិក្បែរៗនោះជួយ ។*
- *លោក រី នៅ ស្គាល់អត្តសញ្ញាណរបស់ពួកបាញ់ចំពាម ហើយប្តឹងទៅនគរបាលមូលដ្ឋាន ប៉ុន្តែពួកគេមិនចាត់ការទេ ដោយនិយាយថាមេប៉ុស្តិ៍មិននៅ ។*

ថ្ងៃទី២២ ខែកក្កដា

**មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាគំរាមប្តឹងសារព័ត៌មានខ្មែរម្ចាស់ស្រុក បើមិនឈប់ផ្សាយអត្ថបទដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះគាត់ទេ**[២២]

- *អតីតតំណាងគណបក្ស សម រង្ស៊ី ម្នាក់ ហើយបច្ចុប្បន្នជាទីប្រឹក្សា និងជានាយករងគណកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា លោក សុខ ផេង បានណែនាំប្រាប់អគ្គនិពន្ធនាយកសារព័ត៌មានខ្មែរម្ចាស់ស្រុកឱ្យឈប់ចេញអត្ថបទ ដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់លោក បើមិនឈប់ទេលោកនឹងប្តឹងសារព័ត៌មាននោះ ។ អត្ថបទនោះបានលើកឡើងអំពី ការចោទប្រកាន់ពីបញ្ហាពុករលួយរបស់លោក ។*
- *អគ្គនិពន្ធនាយក នៃសារព័ត៌មាននោះបានបដិសេធមិនព្រមបញ្ឈប់ការផ្សាយរិះគន់នោះទេ ដោយបានប្រាប់សារព័ត៌មានកម្ពុជាថ្មីថា លោក សុខ ផេង គឺគ្រាន់តែជាប្រជាពលរដ្ឋម្នាក់តែប៉ុណ្ណោះ ពុំមែនជាព្រះមហាក្សត្រដែល (ច្បាប់រដ្ឋធម្មនុញ្ញ ការពារកេរ្តិ៍ឈ្មោះទេ) ។*

ថ្ងៃទី១២ ខែកក្កដា

**អ្នកសារព័ត៌មានគាំទ្រគណបក្ស សម រង្ស៊ី ត្រូវបាញ់សម្លាប់នៅភ្នំពេញ**[២៣]

- *នៅវេលាម៉ោង ៧ ល្ងាច ថ្ងៃទី១១ ខែកក្កដា (២ សប្តាហ៍មុនថ្ងៃបោះឆ្នោតជាតិ) លោក ឃឹម សំបូរ អ្នកសារព័ត៌មានរបស់សារព័ត៌មានមនសិការខ្មែរ ដែលជាសារព័ត៌មានភាសាខ្មែរគាំទ្រគណបក្ស សម រង្ស៊ី ត្រូវបានគេ បាញ់៣គ្រាប់នៅកណ្តាលវាល ដោយបុរសកាន់កាំភ្លើង២ នាក់*

---

[២២] សារព័ត៌មានកម្ពុជាថ្មី: *សុខ ផេង គម្រាមប្តឹងសារព័ត៌មានខ្មែរម្ចាស់ស្រុក បើនៅតែបន្តផ្សាយប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់លោក* ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ។

[២៣] ឌី ឃែមបូឌា ដេលី : *អ្នកសារព័ត៌មានម្នាក់ត្រូវបាញ់សម្លាប់នៅភ្នំពេញ* ថ្ងៃទី១២-១៣ ខែកក្កដា ឆ្នាំ២០០៨ ។ សូមមើល: http://www.ahrchk.net/ua/mainfile.php/2008/2929/ ; http://idscambodia.blogspot.com/2009/03/cambodian-journalist-from-opposition.html ;

http://www.unhchr.ch/huricane/huricane.nsf/0/B2405F98C29BF6D2C125748800382C05?opendocument ។

ថ្ងៃទី២៩ ខែកក្កដា

*ជិះទោចក្រយានយន្តមួយគ្រឿង។ កូនប្រុសរបស់លោក ឈ្មោះ ខាត់ សារិន អាយុ ២១ ឆ្នាំ ក៏ត្រូវបានគេបាញ់សម្លាប់ក្នុងព្រឹត្តិការណ៍នោះដែរ។*

- *លោក សំបូរ បានសរសេរអត្ថបទរិះគន់ជាច្រើនដែលដាក់ឈ្មោះថា" ដោយស្រីកា ឬ ឈ្មោះថា ដែន សុរិទ្ធ" ដែលតែងតែរិះគន់គណបក្សកាន់អំណាច និងមន្ត្រីជាន់ខ្ពស់ ក្នុងរដ្ឋាភិបាល។*
- *ក្នុងចំណោមអត្ថបទរិះគន់ថ្មីៗរបស់លោករួមមាន អត្ថបទមួយសរសេរចោទ ប្រកាន់មន្ត្រីជាន់ខ្ពស់ម្នាក់ ដែលបានបញ្ជាឱ្យចាប់ជម្រិតបុគ្គលិកកាស៊ីណូ។*

**ឧត្តមសេនីយ៍ម្នាក់បានវាយអ្នកសារព័ត៌មានរបស់សារព័ត៌មានកោះសន្តិភាព**[២៤]

- *អ្នកសារព័ត៌មានកោះសន្តិភាពម្នាក់ឈ្មោះ រស់ សុភីណា ប្រចាំនៅ ស្រុក ស្ទឹងហាវ ខេត្តព្រះសីហនុ ត្រូវបានមេបញ្ជាការកងរាជអាវុធហត្ថ ឧត្តមសេនីយ៍ផ្កាយ៣ ឈ្មោះ ង៉ែត វណ្ណថា ទះកំភ្លៀង។ បន្ទាប់ពីលោកបានសសេរឈ្មោះ ឧត្តមសេនីយ៍រូបនេះនៅក្នុងអត្ថបទថ្ងៃទី២៤ ខែកក្កដា ថា មានការពាក់ព័ន្ធជាមួយការដឹកឈើខុសច្បាប់។*
- *ការវាយដំនោះបានកើតឡើង នៅក្នុងការិយាល័យកងរាជអាវុធហត្ថស្រុកនៅថ្ងៃទី២៥ ខែកក្កដា ក្រោយពីគេបានហៅអ្នកសារព័ត៌មាននោះទៅសាកសួរ។ ឧត្តមសេនីយ៍នោះបានបញ្ជាឱ្យអ្នកសារព័ត៌មាននោះធ្វើការកែតម្រូវ។ ប៉ុន្តែ លោក រស់ សូភីណា បាននិយាយថា លោកមិនកែតម្រូវទេ ហើយសំណូមពរឱ្យលោកឧត្តមសេនីយ៍កែតម្រូវដោយខ្លួនឯង។ ពេលនោះស្រាប់តែលោកឧត្តមសេនីយ៍ បានវាយលោកចំមុខព្រមទាំងបានគំរាមលោកទៀតផង។*
- *នៅថ្ងៃទី២៨ ខែកក្កដា លោក រស់ សូភីណា បានដាក់ពាក្យបណ្តឹងទៅទីបញ្ជាការកងរាជអាវុធខេត្ត ហើយនៅថ្ងៃទី៦ ខែសីហា លោកបានដាក់ពាក្យបណ្តឹងអំពីការវាយដំលើរាងកាយនោះ ទៅតុលាការខេត្តព្រះសីហនុ ដោយទារជម្ងឺចិត្តចំនួន ៥.០០០ ដុល្លាអាមេរិក។*
- *នៅថ្ងៃទី១១ ខែសីហា បុរសទាំងពីរនាក់នេះបានជួបគ្នា ហើយឧត្តមសេនីយ៍ ង៉ែត វណ្ណថា បានសុំទោស។ អ្នកសារព័ត៌មានក៏បានដកពាក្យបណ្តឹងវិញ។ ហើយចុងក្រោយពុំមានការសរសេរកែតម្រូវលើសារព័ត៌មានទេ។*

[២៤] សារព័ត៌មានកោះសន្តិភាព: *កងរាជអាវុធហត្ថវាយអ្នកយកព័ត៌មាន* ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨។

ថ្ងៃទី២៩ ខែកក្កដា

**ស្ថានីយវិទ្យុ FM ៩៣.៥ ត្រូវបានបិទ**[២៥]

- *ក្រសួងព័ត៌មានបានបញ្ជាឱ្យស្ថានីយវិទ្យុមហានគរ FM ៩៣.៥ មានទីតាំង នៅឃុំជើងឯក ខណ្ឌដង្កោ បញ្ឈប់ការផ្សាយសម្លេងរបស់ខ្លួននៅយប់ថ្ងៃទី២៦ ខែកក្កដា ។*
- *លោកនាយកស្ថានីយ គង់ ចិត្រា បាននិយាយនៅថ្ងៃទី២៧ ខែកក្កដា បញ្ជាក់ថា អាជ្ញាធរបានបញ្ជាឱ្យបិទស្ថានីយកាលពីប៉ុន្មានថ្ងៃមុននេះ ។*
- *ការបិទស្ថានីយត្រូវបានរាយការណ៍ថា ដោយសារតែស្ថានីយនេះ បានផ្សាយកម្មវិធីក្នុងនាមគណបក្សសម រង្ស៊ី ក្រោយកាលបរិច្ឆេទយុទ្ធនាការបោះឆ្នោតជាតិជាសកលត្រូវបានចប់ ។*

ថ្ងៃទី១៨ ខែសីហា

**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាថ្កោលទោសការវាយប្រហារលើសារព័ត៌មាន**[២៦]

- *នៅថ្ងៃទី១៨ ខែសីហា អគ្គនិពន្ធនាយកនៃសារព័ត៌មាន ច្បាស់ការ ឈ្មោះ យុត ខាត់ណា និងតំណាងសារព័ត៌មាន ដំណឹងខ្មែរពិសេស តែ លីមហាក់ ត្រូវបានអ្នកលក់សាំងឈ្មោះ ហ៊ីម និងជំនួយការពីរនាក់ វាយដំយ៉ាងធ្ងន់ធ្ងរនៅខេត្តសៀមរាប ។*
- *ឧប្បត្តិហេតុនេះបានកើតឡើងក្រោយពេលដែលពួកគេទាំងពីរនាក់បានឃើញ រថយន្តដឹកសាំងមួយគ្រឿងរបស់លោក ហ៊ីម បង្កគ្រោះថ្នាក់ចរាចរណ៍នៅភូមិដៃអាវ ឃុំស្រែណូយ ស្រុកវ៉ារិន្ទ ខេត្តសៀមរាប ។*
- *បន្ទាប់ពីបានរាយការណ៍អំពីឧប្បត្តិហេតុគ្រោះថ្នាក់ចរាចរនោះ បុរសទាំងពីរនាក់ ត្រូវបានរាយការណ៍ថា ត្រូវបានទទួលការវាយដំលើរាងកាយ ដោយលោក ហ៊ីម និងជំនួយការពីរនាក់ទៀត ។*

ថ្ងៃទី២០ ខែសីហា

**កូនស្រី សម្តេចនាយករដ្ឋមន្ត្រីទាមទារឱ្យទស្សនាវដ្តីប្រមូលអត្ថបទចែកផ្សាយមកវិញ**[២៧]

- *កូនស្រីសម្តេចនាយករដ្ឋមន្ត្រី ឈ្មោះ ហ៊ុន ម៉ាណា បានដាក់ពាក្យបណ្តឹងទៅក្រសួងព័ត៌មានទាមទារឱ្យទស្សនាវដ្តី ឈ្មោះ សោភ័ណ្ឌ ប្រមូលយកអត្ថបទដែលបានសរសេររិះគន់ស្ថានីយទូរទស្សន៍បាយ័នដែលនាងជាអ្នកកាន់កាប់ ។*

---

[២៥] សារព័ត៌មានរស្មីកម្ពុជា: *ស្ថានីយវិទ្យុ FM ៩៣.៥ បញ្ឈប់ការផ្សាយ* ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨ ។

[២៦] សារព័ត៌មានកោះសន្តិភាព: *មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានរិះគន់ការវាយប្រហារលើអ្នកសារព័ត៌មានថា ជាការរំលោភលើសេរីភាពនៃការបញ្ចេញមតិ* ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ។

[២៧] ឌី ឃែមបូឌា ដេលី : *កូនស្រីនាយករដ្ឋមន្ត្រី បានទាមទារឱ្យទស្សនាវដ្តី ប្រមូលអត្ថបទមកវិញ* ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨។

សូមមើល: http://ki-media.blogspot.com/2008/08/cpp-real-life-soap-opera-at-bayon-tv.html; http://www.phnompenhpost.com/index.php/component/option,com_jcs/Itemid,52/crestrictid,21287/task,add/; http://www.asiafinest.com/forum/lofiversion/index.php/t171469.html ។

**ថ្ងៃទី២១ ខែសីហា**

*អត្ថបទនោះបានសរសេរថា មានបុគ្គលិកពាក់ព័ន្ធក្នុងរឿងស្នេហាត្រីកោណ ហើយបន្ថែមថា បុគ្គលិកបណ្ដាញម្នាក់គឺមិន "ឆ្លាត" នេះបើតាមការអះអាងរបស់ទូរទស្សន៍បាយ័ននៅក្នុងសេចក្ដីប្រកាសព័ត៌មាន ។*

- *សេចក្ដីប្រកាសព័ត៌មានបានបញ្ជាក់ថា អត្ថបទនោះ "បានបង្ខូចឈ្មោះ និងបំបាក់ទឹកចិត្ត" បុគ្គលិករបស់ស្ថានីយ ព្រមទាំងនិយាយថា កេរ្តិ៍ឈ្មោះមួយផ្នែករបស់អ្នកសារព័ត៌មាន ឈ្មោះ សាន ប៊ុនធឿន ត្រូវបានអាប់ឱន ។ ស្ថានីយបាយ័នក៏បានអះអាងថា អ្នកសារព័ត៌មាននោះបានជម្រិតទារប្រាក់ ៣.០០០ ដុល្លាអាមេរិក ពីអ្នកអានព័ត៌មានទូរទស្សន៍បាយ័នម្នាក់ ។*

**អ្នកសារព័ត៌មានជំទាស់ភ័យខ្លាចចំពោះនគរបាលសម្ងាត់ឃ្លាំមើលពួកគេ**[២៨]

- *អ្នកសារព័ត៌មាន ២ នាក់ នៃសារព័ត៌មានមនសិការខ្មែរ ដែលគាំទ្រគណបក្សសម រង្ស៊ី មានការភ័យខ្លាច ដោយមានកម្លាំងនគរបាលធ្វើការស៊ើបអង្កេតសម្ងាត់អំពីសកម្មភាពរបស់ពួកលោក ។*
- *លោក វង្ស សុភ័ក្រ និងបងប្រុស ឈ្មោះ វង្ស សុភាព ទាំងពីរនាក់ជាអ្នកសារព័ត៌មាន នៃសារព័ត៌មាននោះ បាននិយាយថា មានមនុស្សមួយក្រុមបានលួចតាមថតរូបពួកលោក ក្នុងពេលបាតុកម្មកាលពីថ្ងៃទី១៧ ខែសីហា នៅខាងមុខការិយាល័យសហជីពសេរីកម្មករ ។ បាតុកម្មនោះបានធ្វើការតវ៉ាចំពោះវត្តមានរបស់កងទ័ពថៃ នៅប្រាសាទព្រះវិហារ ។*
- *លោក វង្ស សុភ័ក្រ បានមានប្រសាសន៍ថា "អ្នកសារព័ត៌មានម្នាក់ នៅក្នុងព្រឹត្តិការណ៍នោះ បានប្រាប់ខ្ញុំថា បុរសនោះបានសាកសួរអំពីខ្ញុំ ហើយចង់ដឹងថាមកពីសារព័ត៌មានណាមួយ ហើយ "ពួកគេបានដឹងថា យើងធ្វើការនៅសារព័ត៌មានមនសិការខ្មែរហើយ" ។*
- *បងប្អូនទាំងពីរនោះ បានអះអាងថា មានមនុស្សតាមដានតាំងពីថ្ងៃទី១២ ខែកក្កដា មកម្ល៉េះ ពេលដែលពួកលោកទៅចូលរួមបុណ្យសព លោក ឃឹម សំបូរ ដែលត្រូវបានបាញ់ស្លាប់ជាមួយកូនលោកកាលពីថ្ងៃមុន ។ លោក វង្ស សុភ័ក្រ បានមានប្រសាសន៍ថា បុរសមួយក្រុមស្លៀកពាក់សម្លេកបំពាក់ធម្មតា បានថតរូបពួកលោកជាច្រើនដង នៅក្នុងព្រឹត្តិការណ៍នោះ ។*

---

[២៨] មាស សុខា-ភ្នំពេញប៉ុស្ដិ៍: *អ្នកសារព័ត៌មាននៃសារព័ត៌មានជំទាស់ភ័យខ្លាចនគរបាលសម្ងាត់ឃ្លាំមើលពួកគេ* ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨ ។ សូមមើល: http://ki-media.blogspot.com/2008/08/opposition-journalists-fear-secret.html

- *លោក វង្ស សុភ័ក្រ្ត បានមានប្រសាសន៍បន្ថែមទៀតថា: ក្រុមជនដែលនោះ បានតាមដានលោក និងបងប្រុសលោក នៅពេលបាតុកម្មរបស់ សហជីពសេរីកម្មករ ។ លោក និងបងប្រុសលោក បានជជែកវែកញែកជាមួយបុរសនោះ ពេលពួកអ្នកទាំងនោះចាប់ថតរូប ហើយបានសុំឱ្យអ្នកទាំងអស់នោះ លុបរូបថតចោលឱ្យអស់ ។*

**ថ្ងៃទី២៧ ខែសីហា**

**មន្ត្រីរាជអាវុធហត្ថបានគំរាមសម្លាប់អ្នកសារព័ត៌មានក្នុងរឿងរត់ពន្ធសាំង**[២៩]

- *មន្ត្រីកងរាជអាវុធហត្ថម្នាក់ឈ្មោះ អាន សូរីដា ហៅច្រឹក បានគំរាមដល់អាយុជីវិតអ្នកសារព័ត៌មាននៃសារព័ត៌មានកម្ពុជាថ្មីម្នាក់ ដែលប្រចាំនៅខេត្តកណ្តាល ដែលបានសរសេរអត្ថបទអំពីការដឹកទំនិញគេចពន្ធពីតាខ្មៅទៅភ្នំពេញ ។*
- *តាមសេចក្តីរាយការណ៍ លោក អាន សូរីដា បានប្រាប់អ្នកសារព័ត៌មានថា លោកនឹងជួលឃាតករឱ្យសម្លាប់ ។ " ចំពោះជីវិតរបស់អ្នកសារព័ត៌មានម្នាក់ ចំណាយតែ ៥.០០០ ដុល្លាអាមេរិកប៉ុណ្ណោះ អាចជួលឃាតករបាញ់សម្លាប់បានហើយ បើហ៊ានជ្រៀតជ្រែកការងាររបស់អ្នកជំនួញ" ។*

**ថ្ងៃទី៣០ ខែកញ្ញា**

**អ្នកសារព័ត៌មានត្រូវបានចាប់ខ្លួនក្រោយពីបានថតរូបយោធា**[៣០]

- *នគរបាលបាននិយាយថា អ្នកសារព័ត៌មានម្នាក់ឈ្មោះ ហ៊ឹម ម៉ៅ អាយុ ៣៤ ឆ្នាំ ដែលបានសរសេរអត្ថបទក្រោមឈ្មោះ កៅ តារា ត្រូវបានចាប់ខ្លួននៅព្រឹកថ្ងៃទី២៨ ខែកញ្ញា ក្រោយពីកើតឧប្បត្តិ-ហេតុហិង្សាមួយផ្ទុះឡើង កាលពីថ្ងៃមុនពេលដែលលោកបានព្យាយាមថតរូបមន្ត្រីកងរាជអាវុធហត្ថ រឹបអូសឈើខុសច្បាប់ ។*
- *នាយនគរបាលប៉ុស្តិ៍ឃុំឈ្មោះ ញាណ សឿន បាននិយាយថាមន្ត្រីកងរាជអាវុធហត្ថ ៤ នាក់ បានចាប់រទេះគោមួយ ដែលដឹកឈើប្រណិត ២ ម៉ែត្រគូប នៅឃុំតាលូ ស្រុកបាកាន ។*

---

[២៩] សារព័ត៌មានកម្ពុជាថ្មី: *មានការរត់ពន្ធសាំងខុសច្បាប់ពីតាខ្មៅមកភ្នំពេញ កងរាជអាវុធហត្ថគំរាម និងប៉ុនប៉ងសម្លាប់អ្នកសារព័ត៌មាន* ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨ ។

[៣០] ឌឹ ឃែមបូឌា ដេលី: *អ្នកសារព័ត៌មានត្រូវបានចាប់ខ្លួនក្រោយពីថតរូបយោធា* ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៨ ។

- *លោក កៅ តារា ជាអ្នកសារព័ត៌មាននៃសារព័ត៌មានភាសាខ្មែរឈ្មោះ រស្មីបាយ័ន បានមកដល់ និងថតរូប ។ នៅពេលនោះមន្ត្រីកងរាជអាវុធហត្ថ បានដកហូតយកម៉ាស៊ីនថត និងប័ណ្ណសារព័ត៌មានរបស់លោក ដែលធ្វើឱ្យអ្នកភូមិជាច្រើនបានខឹងយ៉ាងខ្លាំង ។ ប្រជាពលរដ្ឋប្រហែល២០នាក់ បានវាយប្រហារលើកងរាជអាវុធហត្ថ ដែលបណ្តាលឱ្យកងកម្លាំង១នាក់ រងរបួស ។*
- *នៅថ្ងៃទី២៩ ខែតុលា តុលាការខេត្តពោធិ៍សាត់ បានចោទប្រកាន់លោកពីបទប្រើប្រាស់អំពើហិង្សា ដែលជាចេតនាបង្កឱ្យមានរបួសស្នាម ។*
- *បច្ចុប្បន្នអ្នកសារព័ត៌មានរូបនេះ កំពុងស្ថិតនៅក្នុងការឃុំឃាំងបណ្តោះអាសន្នរង់ចាំការកាត់ទោសក្នុងពន្ធនាគារខេត្តពោធិ៍សាត់ ។*

**ថ្ងៃទី២៣ ខែធ្នូ**

**មេធាវីរបស់សម្តេចក្រុមព្រះស្នើឱ្យអគ្គនិពន្ធនាយកសារព័ត៌មានមនសិការខ្មែរផ្តល់បញ្ជីឈ្មោះ** [៣១]

- *ការិយាល័យច្បាប់របស់សម្តេចក្រុមព្រះ បានផ្ញើលិខិតមួយច្បាប់ទៅអគ្គនិពន្ធនាយកសារព័ត៌មានមនសិការខ្មែរ ទាមទារឱ្យលោកផ្សាយបញ្ជីពាក់ព័ន្ធ ដើម្បីបង្ហាញឈ្មោះរដ្ឋមន្ត្រី ដែលសម្តេចក្រុមព្រះបានស្នើ ដើម្បីតែងតាំងទៅព្រះបរមរាជវាំង ។*
- *លិខិតនោះបានគម្រាមចាត់វិធានការច្បាប់ បើសារព័ត៌មាននោះមិនបានផ្សាយបញ្ជីឈ្មោះទេ ។*
- *អគ្គនិពន្ធនាយក លោក ដាំ សិទ្ធិ បានមានប្រសាសន៍ថា ការចាត់ការរបស់មេធាវីសម្តេចក្រុមព្រះនេះ បានបង្កឱ្យមានការគំរាមកំហែងមកលើសារព័ត៌មាន ។*

**ថ្ងៃទី៣០ ខែធ្នូ**

**អ្នកភូមិបាននិយាយថា អ្នកសារព័ត៌មានត្រូវបានចាប់ឃុំក្នុងពន្ធនាគារពាក់ព័ន្ធបញ្ហាដីធ្លី នៅសៀមរាប** [៣២]

- *ក្នុងចំណោមមនុស្ស ៣ នាក់ ដែលត្រូវបានចាប់ខ្លួន មានម្នាក់ជាអ្នកយកព័ត៌មាននៅថ្ងៃទី២៦ ខែធ្នូ នៅក្នុងបញ្ហាជម្លោះដី ៤៧៥ ហិកតា នៅស្រុកជីក្រែង ខេត្តសៀមរាប ។*
- *លោក ស៊ីន សំឡី អាយុ ២៨ ឆ្នាំ ជាអ្នកយកព័ត៌មាននៃសារព័ត៌មានសង្គមខ្មែរ ត្រូវបានចាប់ខ្លួនជាមួយតំណាងអ្នកភូមិពីរនាក់ ដោយព្រះរាជអាជ្ញាអមតុលាការខេត្ត ឈ្មោះ នួន សាន ។*

---

[៣១] សារព័ត៌មានកម្ពុជាថ្មី: *មេធាវីរបស់ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ស្នើឱ្យអគ្គនិពន្ធនាយកសារព័ត៌មានមនសិកាខ្មែរផ្តល់បញ្ជីឈ្មោះ* ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ ។

[៣២] ឌី ឃែមបូឌា ដេលី: *អ្នកភូមិបាននិយាយថា អ្នកសារព័ត៌មានត្រូវបានចាប់ឃុំក្នុងពន្ធនាគារពាក់ព័ន្ធបញ្ហាជម្លោះនៅសៀមរាប* ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។

- *លោក ស៊ីន សំឡី បានសរសេរនៅក្នុងសារព័ត៌មានអំពីជម្លោះរឿងបញ្ហាដី ចំនួន ៤៧៥ ហិកតា នោះ ។ ការចាប់អ្នកទាំងបីនាក់នោះ ធ្វើឡើងដោយគ្មាន ការចោទប្រកាន់ឱ្យបានច្បាស់លាស់ទេ ។ អ្នកទាំងបីនាក់នោះត្រូវបានដោះលែងឱ្យនៅក្រៅឃុំ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ។*

**ថ្ងៃទី២ ខែមករា ឆ្នាំ២០០៩**

**លោកនាយករងពន្ធនាគារខេត្តបានក្លាយជាអ្នកទោសជាមួយអ្នកសារព័ត៌មានពេលព្រឹក**[៣៣]

- *អ្នកសារព័ត៌មានម្នាក់ ត្រូវបានបញ្ជូនទៅឃុំឃាំងបណ្ដោះអាសន្ន នៅថ្ងៃទី២៩ ខែធ្នូ ជាមួយ នាយករងពន្ធនាគារខេត្តព្រះវិហារ ក្រោយពីបុរសទាំងពីរនាក់នេះ ត្រូវបានចោទប្រកាន់ពីបទលួច លក់ដីរដ្ឋ ។*
- *អ្នកសារព័ត៌មាន ឈ្មោះ សូ សុផល បម្រើការសារព័ត៌មានពេលព្រឹក ត្រូវបានចោទប្រកាន់ពីបទ រំលោភច្បាប់ដីធ្លី ។ នាយករងពន្ធនាគារ ឈ្មោះ ថាច់ សុគន្ធី ពីបទឆបោក ។*
- *ការចាប់ខ្លួនត្រូវបានធ្វើតាមបញ្ជារបស់អភិបាលខេត្ត ព្រាប តាន់ ។*

**ថ្ងៃទី១៦ ខែមករា**

**នគរបាលបានអះអាងថា អ្នកសារព័ត៌មានម្នាក់ត្រូវបានគេចាក់ ហើយបានស្លាប់នៅមន្ទីរ ពេទ្យ**[៣៤]

- *អ្នកសារព័ត៌មានម្នាក់បានស្លាប់ក្រោយពីត្រូវបានចាក់ ១០ កាំបិត ដោយបុរស ២នាក់ នៅខ័ណ្ឌ សែនសុខ នៅក្នុងព្រឹត្តិការណ៍មួយ ដែលនគរបាលអះអាងថា ជាអំពើប្លន់ ដែលខុសគោលដៅ ទៅវិញ ។*
- *លោក បាន សុង អាយុ ៤៤ ឆ្នាំ ជាអ្នកសារព័ត៌មាននៃសារព័ត៌មាន មាតុភូមិ ត្រូវបានបុរស២នាក់ វាយប្រហារដោយចាក់នឹងកាំបិតនៅល្ងាចមួយ ក្រោយពីគេបានហៅលោកឱ្យឈប់ទោចក្រយាន យន្តរបស់លោក នៅតាមផ្លូវ ជាតិលេខ៥ ។ នគរបាលបាននិយាយថា លោក បាន សុង បាន ព្យាយាមវាយតដៃជាមួយជនល្មើស ។*

---

[៣៣] សារព័ត៌មានកោះសន្តិភាព: *លោកនាយករងពន្ធនាគារខេត្តបានក្លាយជាអ្នកទោសជាមួយអ្នកសារព័ត៌មានពេលព្រឹក* ថ្ងៃទី២ ខែមករា ឆ្នាំ២០០៩ ។

[៣៤] ឌឺ ឃែមបូឌា ដេលី: *នគរបាលបានអះអាងថា អ្នកសារព័ត៌មានម្នាក់ត្រូវបានគេចាក់ ហើយស្លាប់នៅមន្ទីរពេទ្យ* ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។

**ថ្ងៃទី៣១ ខែមករា**

**អ្នកសារព័ត៌មានចោទប្រកាន់មន្ត្រីម្នាក់ ថាបានបាញ់កាំភ្លើងមកលើខ្លួន**[៣៥]

- *មន្ត្រីកងរាជអាវុធហត្ថម្នាក់ ត្រូវបានចោទប្រកាន់ថា បានបាញ់កាំភ្លើង ៣ គ្រាប់ ដោយប្រើប្រាស់កាំភ្លើងខ្លីរបស់លោក សំដៅទៅលើក្បាលរបស់អ្នកសារព័ត៌មានម្នាក់នៅខេត្តកំពង់ឆ្នាំងកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩។*
- *អ្នកសារព័ត៌មាន ឈ្មោះ លឹម លីហៀង អាយុ ៤១ ឆ្នាំ បម្រើការងារឱ្យសារព័ត៌មានមួយជាភាសាខ្មែរឈ្មោះ ដំណឹងថ្ងៃនេះ កំពុងយកព័ត៌មានអំពីការដឹកឈើខុសច្បាប់តាមរថភ្លើង ពេលនោះមន្ត្រីកងរាជអាវុធហត្ថបានបាញ់មកលើលោក បើតាមសម្តីរបស់មិត្តភក្តិលោកម្នាក់ឈ្មោះ ខាន់ សុខុម។*
- *ឧប្បត្តិហេតុនេះបានកើតឡើងនៅ ស្ថានីយរមាស ក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ មេព្រៃឈ្មោះ គង់ សុផល ហុង សុជាតិ និង ធី បានមានប្រសាសន៍ថា មន្ត្រីកងរាជអាវុធហត្ថ ឈ្មោះ ស្វាយ វដ្ឋា នោះ ជាអ្នកការពាររថភ្លើង បានរត់តម្រង់ទៅរកអ្នកសារព័ត៌មាន លឹម លីហៀង ហើយស្រែកដាក់លោក។ លោក ស្វាយ វដ្ឋា បានបាញ់៣គ្រាប់ឡើងលើ ហើយដកហូតយកម៉ាស៊ីនថតរូបរបស់អ្នកសារព័ត៌មាននោះ និងមិនសងម្ចាស់វិញទេ។*

**ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩**

**មន្ត្រីនគរបាលស្រុកព្រៃនប់វាយក្បាលអ្នកសារព័ត៌មាន ហើយចាប់ដកហូតម៉ាស៊ីនថតរូប**[៣៦]

- *អ្នកសារព័ត៌មានកោះសុវណ្ណភូមិ ត្រូវបានវាយដំបណ្តាលឱ្យរងរបួស ដោយមន្ត្រីនគរបាលស្រុកព្រៃនប់ នៅក្នុងពិធីអាពាហ៍ពិពាហ៍មួយក្នុងខេត្តព្រះសីហនុ នៅថ្ងៃទី១៩ ខែកុម្ភៈ បន្ទាប់ពីលោកថតរូបមន្ត្រីនគរបាលម្នាក់នោះ កំពុងអង្គុយជិតស្ត្រីសក់ក្រហមម្នាក់។*
- *លោក ស៊ុន យ៉ាត ត្រូវបានមន្ត្រីនគរបាល ឈ្មោះ ហួ ឃៃ បានវាយលោកឱ្យរបួសក្បាលយ៉ាងធ្ងន់ធ្ងរ ហើយថែមទាំងបានដកហូតយកម៉ាស៊ីនថតរូបរបស់លោកទៀតផង។*

□□□

[៣៥] ឌី ឃែមបូឌា ដេលី: *អ្នកសារព័ត៌មានចោទប្រកាន់មន្ត្រីថាបានបាញ់កាំភ្លើងមកលើខ្លួន* ថ្ងៃទី៣១ ខែមករា-ថ្ងៃទី១ ខែកុម្ភៈ ២០០៩ ។

[៣៦] សារព័ត៌មានរស្មីកម្ពុជា: *មន្ត្រីនគរបាលស្រុកព្រៃនប់វាយក្បាលអ្នកសារព័ត៌មាន ហើយចាប់ដកហូតម៉ាស៊ីនថតរូប* ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩។

# ៤. អនុសាសន៍

អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភាជាតិ ព្រមទាំងសហគមន៍ជាតិ និងអន្តរជាតិ (ដើម្បីតស៊ូមតិឱ្យមានការចាត់វិធានការដូចតទៅនេះ)[៣៧]:

## កំណែទម្រង់ច្បាប់

- មានតែច្បាប់ស្តីពីសារព័ត៌មានទេ ដែលចែងយ៉ាងច្បាស់ថា ត្រូវប្រើក្នុងការដោះស្រាយ ការប្រកាន់ពី បទបរិហារកេរ្តិ៍ បទផ្សាយព័ត៌មានមិនពិត និងអំពើពាក់ព័ន្ធ។
- លប់ចោលមាត្រា ១២ នៃច្បាប់ស្តីពីសារព័ត៌មាន (ពាក់ព័ន្ធសន្តិសុខជាតិ និងស្ថិរភាពនយោបាយ) ដែលត្រូវបានប្រើខុសជាប្រចាំ។ ប្រសិនបើរដ្ឋាភិបាល និងរដ្ឋសភាជាតិ មិនត្រៀមខ្លួនធ្វើបែបនេះទេ យ៉ាងតិចណាស់ ក៏មាត្រានេះត្រូវធ្វើវិសោធនកម្មឱ្យបានច្រើន ដើម្បីធានាឱ្យបាននូវៈ
  - ពាក្យ "ស្ថិរភាពនយោបាយ" ត្រូវលប់ចេញ ដោយវាកំហិតយ៉ាងខ្លាំងដល់សិទ្ធិប្រជាពលរដ្ឋខ្មែរ សេរីភាពក្នុងការបញ្ចេញមតិយោបល់ពីរដ្ឋាភិបាល និងគណបក្សនយោបាយនានា។
  - "សន្តិសុខជាតិ" ត្រូវបានផ្តល់និយមន័យយ៉ាងច្បាស់លាស់ពិសេស ដកចេញនូវបញ្ហាដែលពាក់ព័ន្ធនយោបាយ និងការពិភាក្សាអំពីគោលនយោបាយ ឬ សកម្មភាពរបស់រដ្ឋាភិបាល។
  - ត្រូវលប់ចោលអំណាចរបស់ក្រសួងព័ត៌មានក្នុងការផ្អាក និងរឹបអូសសារព័ត៌មាន ដោយអំណាចនេះ បណ្តាលឱ្យមានការត្រួតពិនិត្យ។
- ធ្វើយ៉ាងណាសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ត្រូវអនុវត្តទៅតាមបទដ្ឋានអន្តរជាតិ ឱ្យបានពេញលេញ ដើម្បីការពារសេរីភាពក្នុងការបញ្ចេញមតិ និងជាពិសេសមិនត្រូវដាក់បទបរិហារកេរ្តិ៍ ឬ ការផ្សាយព័ត៌មានមិនពិតជាបទព្រហ្មទណ្ឌ ឬ បទល្មើសស្រដៀងគ្នានៅក្នុងច្បាប់នេះទេ។

---

[៣៧] អនុសាសន៍ទាំងអស់នេះ គឺត្រូវបានសរសេរសារជាថ្មីម្តងទៀត ចេញពីរបាយការណ៍ លីកាដូ ដែលចេញផ្សាយកាលពីខែឧសភា ឆ្នាំ២០០៨ កន្លងទៅថ្មីៗនេះ គឺមានចំណងជើងថា *" ការស្វែងយល់ចំពោះ អត្ថន័យដែលមើលមិនឃើញ: នយោបាយ ប្រាក់កាស និងការភ័យខ្លាច គ្រប់គ្រងប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា ដោយរបៀបណា "*។ ជាសរុបអនុសាសន៍ទាំងអស់នេះ រដ្ឋាភិបាលកម្ពុជា មិនបានយកចាត់វិធានការនៅឡើយ។

- ធ្វើយ៉ាងណាឱ្យសេចក្តីព្រាងច្បាប់ថ្មីស្តីពី "សេរីភាពក្នុងការទទួលព័ត៌មាន" ស្របតាមបទដ្ឋានអន្តរជាតិ ហើយកុំដាក់ការហាមប្រាមទាំងឡាយឱ្យទៅជាអំពើស្របច្បាប់ ឬ ធ្វើឱ្យការហាមប្រាមស្តីពីការទទួលបានព័ត៌មាននៅកម្ពុជាបច្ចុប្បន្ន កាន់តែតឹងតែងជាងមុនឡើយ។

## កម្មសិទ្ធិករ និងការផ្តល់អាជ្ញាប័ណ្ណប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិក

- ត្រូវបង្កើតក្របខណ្ឌសមភាព និងសេរីក្នុងការផ្តល់អាជ្ញាប័ណ្ណវិទ្យុ និងទូរទស្សន៍ស្របតាមបទដ្ឋានអន្តរជាតិ ចំពោះសេរីភាពនៃការបញ្ចេញមតិ និងប្រព័ន្ធផ្សាយផ្សាយព័ត៌មាន។
- ដើម្បីធ្វើកិច្ចការខាងលើនេះបាន ត្រូវធ្វើការសិក្សាទូលំទូលាយឯករាជ្យមួយ ដើម្បីត្រួតពិនិត្យមើលការអនុវត្តន៍ល្អៗ នៅអន្តរជាតិក្នុងការផ្តល់អាជ្ញាប័ណ្ណដល់ប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិក ព្រមទាំងបញ្ហាបច្ចេកទេសពាក់ព័ន្ធមួយចំនួន (ដូចជា រលកធាតុអាកាស) នៅកម្ពុជា និងធ្វើអនុសាសន៍ដល់ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណកម្ពុជា។
- សូមឱ្យក្រសួងព័ត៌មានឈប់គ្រប់គ្រងស្ថានីយទូរទស្សន៍ និងវិទ្យុជាតិ (**ទទក** AM ៩១៨ និង FM ៩៦) ដើម្បីក្លាយជាសេវាសាធារណៈស្វយ័តមួយដោយរួមមានៈ
  - មូលនិធិស្វយ័តសម្រាប់ស្ថានីយទាំងនោះ ដែលត្រូវបានយល់ព្រមដោយរដ្ឋសភាជាតិ។
  - តែងតាំងនាយកស្ថានីយនានាដែលជាមនុស្សឯករាជ្យ ដោយរដ្ឋសភាជាតិ (ពុំមែនជាមន្ត្រីរាជរដ្ឋាភិបាលដូចសព្វថ្ងៃនេះទេ) និងមានជំនាញចាំបាច់នានា។
  - សូមឱ្យមានការហាមប្រាមច្បាស់លាស់នូវការគ្រប់គ្រងដោយផ្ទាល់ពីក្រសួងព័ត៌មាន ឬ ស្ថាប័នណាមួយរបស់រដ្ឋ។

## និទណ្ឌភាព ការប្រើប្រាស់ច្បាប់ខុសទិសដៅ និងការត្រួតពិនិត្យ

- សូមឱ្យនគរបាល និងតុលាការ ធ្វើការស៊ើបអង្កេតជាថ្មីចំពោះរាល់ករណីឃាតកម្មលើអ្នកសារព័ត៌មាននៅកម្ពុជា ដែលបានកើតឡើងតាំងពីឆ្នាំ១៩៩៣ មក។
- សូមចាត់វិធានការយ៉ាងមានប្រសិទ្ធិភាព និងជាបន្ទាន់ដើម្បីស៊ើបអង្កេត និងដាក់ទណ្ឌកម្មដល់ករណីអំពើរំខានគំរាមកំហែង អំពើហិង្សា ឬការជ្រៀតជ្រែកដល់កិច្ចការអ្នកសារព័ត៌មានដែលត្រូវបានរាយការណ៍។

- ជាពិសេស សូមឱ្យការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងផ្តន្ទាទោសព្រហ្មទណ្ឌ នូវរាល់ករណីហិង្សាមកលើអ្នកសារព័ត៌មាន។
- សូមឱ្យមន្ត្រី និងមន្ត្រីសាធារណៈសំខាន់ៗមួយចំនួនឯទៀតបង្ហាញនូវការអត់អោនចំពោះការរិះគន់ និងគោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន ហើយផ្អាកប្តឹងអ្នកសារព័ត៌មានបទព្រហ្មទណ្ឌ។
- (រហូតដល់ច្បាប់ស្តីពីសារព័ត៌មានត្រូវបានធ្វើវិសោធនកម្ម) សូមក្រសួងមហាផ្ទៃមេត្តាកុំផ្អាកអាជ្ញាប័ណ្ណសារព័ត៌មាន ឬ សូមមេត្តាកុំរឹបអូសសម្ភារៈទាំងឡាយដែលបានបោះពុម្ព។
- សូមមេត្តាឈប់ត្រួតពិនិត្យនូវព័ត៌មានរបស់ **ទទក**។

## ***អនុសាសន៍ចំពោះនិយោជិក-និយោជក របស់ប្រព័ន្ធផ្សាយព័ត៌មាន អ្នកតស៊ូមតិ ដើម្បីសេរីភាពនៃការបញ្ចេញមតិ និងអង្គការមិនមែនរដ្ឋាភិបាលៈ***

- គ្រប់ប្រព័ន្ធផ្សាយព័ត៌មានទាំងអស់ (រួមទាំងប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិក) គួរបង្កើត និងគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ។
- ម្ចាស់ប្រព័ន្ធផ្សាយព័ត៌មានម្នាក់ៗ អ្នកគ្រប់គ្រង ឬ អ្នកបោះពុម្ពផ្សាយគួរចាត់វិធានការ ដើម្បីលើកកម្ពស់បទដ្ឋានអ្នកសារព័ត៌មានល្អ ដូចជាផ្តល់ប្រាក់បៀវត្សរ៍ដែលអាចឱ្យអ្នកយកព័ត៌មាន និងបណ្ណាធិការដោះស្រាយជីវភាពបានល្អ ធានាយ៉ាងណាឱ្យបុគ្គលិក (អចិន្ត្រៃយ៍ ឬ គ្មានកិច្ចសន្យា) មិនត្រូវបង់ប្រាក់ឱ្យបណ្ណាធិការ ដើម្បីបានចុះផ្សាយអត្ថបទរបស់ពួកគេទេ។ សូមឱ្យលើកទឹកចិត្តបុគ្គលិកឱ្យប្រកាន់ខ្ជាប់នូវក្រមសីលធម៌។ សូមធានាឱ្យមានឯករាជ្យក្នុងបទអត្ថាធិប្បាយនៅតាមច្រកចែកចាយរបស់ប្រព័ន្ធផ្សាយព័ត៌មានពីឥទ្ធិពលនយោបាយ ឬ ឥទ្ធិពលផ្សេងទៀត។ សូមបង្កើតឱ្យមានយន្តការសម្រាប់ប្តឹងសម្រាប់បុគ្គលិក និងអ្នកអាន/អ្នកមើល/អ្នកស្តាប់ ដើម្បីរាយការណ៍នូវការរំលោភលើក្រមសីលធម៌។
- អ្នកសារព័ត៌មានគួរតែដើរតួអ្នកនាំមុខគេ ក្នុងការតស៊ូមតិដើម្បីឱ្យមានសេរីភាពក្នុងប្រព័ន្ធផ្សាយព័ត៌មាន និងការពារ រួមមាន តាមរយៈការផ្លាស់ប្តូរប្រព័ន្ធច្បាប់ កំណែទម្រង់ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណដល់ប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិក ហើយដោយការដាក់ និងថ្កោលទោសករណីគំរាមកំហែង និងរំលោភនីមួយៗមកលើអ្នកធ្វើការក្នុងប្រព័ន្ធផ្សាយព័ត៌មាននានា។

- ត្រូវតែខិតខំប្រឹងប្រែងដើម្បីឃ្លាំមើលនូវមាតិការបស់ប្រព័ន្ធផ្សាយព័ត៌មាន (ជាពិសេស ទូរទស្សន៍ និងវិទ្យុរបស់រដ្ឋ) ហើយត្រូវបញ្ជាក់ឱ្យច្បាស់នូវវិសមភាព និងកង្វះសមភាពនៅក្នុងការផ្សាយព័ត៌មាន ។
- ពង្រឹងការរាយការណ៍ និងចងក្រងជាឯកសារនូវករណីវាយប្រហារ និងគំរាមកំហែងមកលើអ្នកសារព័ត៌មានម្នាក់ៗ ហើយផ្សព្វផ្សាយករណីទាំងនោះជាសាធារណៈនៅទីណាដែលអាចធ្វើបាន ដើម្បីបង្កើនការយល់ដឹងឱ្យបានកាន់តែខ្ពស់ជាងមុន ចំពោះករណីគំរាមកំហែងមកលើសេរីភាពនៃប្រព័ន្ធផ្សាយព័ត៌មាន ។
- ពង្រឹងការចងក្រង ទំនាក់ទំនងរវាងសមាគមប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា និងអ្នកសារព័ត៌មាននីមួយៗ ជាមួយក្រុមសេរីភាពនៃការបញ្ចេញមតិក្នុងតំបន់ និងអន្តរជាតិ ដើម្បីធានាឱ្យមានការឆ្លើយតបកាន់តែធំឡើង ចំពោះករណីវាយប្រហារ និងការគំរាមកំហែងជាក់លាក់នីមួយៗមកលើអ្នកសារព័ត៌មាន ។
- ពង្រីកកម្មវិធីហ្វឹកហ្វឺនសារព័ត៌មាន ដោយដាក់បញ្ចូលនូវជំនាញពាណិជ្ជកម្មដល់អ្នកគ្រប់គ្រងជាន់ខ្ពស់ដូចជា ជំនាញទីផ្សារ ការទិញ និងការផ្សាយពាណិជ្ជកម្មលក់ ជាដើម ។
- អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល (ដោយមិនគិតថាពួកគេធ្វើការលើបញ្ហាសេរីភាពនៃការបញ្ចេញមតិ ឬ អត់ទេ) គួរលើកកម្ពស់យ៉ាងសកម្មនូវប្រព័ន្ធផ្សាយព័ត៌មានសេរី យុត្តិធម៌ និងមានការទទួលខុសត្រូវដោយរួមមានការអនុម័តនូវគោលនយោបាយ ដែលមិនបង់ថវិការឱ្យអ្នកសារព័ត៌មាន តាមវិធីណាមួយដើម្បីចុះផ្សាយព័ត៌មានឡើយ (រួមទាំងមិនបង់ថវិកាឱ្យពួកគេដើម្បីចូលរួមសន្និសីទសារព័ត៌មាន) ។ ជៀសវាងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុទៅ (ដូចជាការផ្សាយពាណិជ្ជកម្មត្រូវបង់ថ្លៃ)ដល់ប្រព័ន្ធផ្សាយសារព័ត៌មានណា ដែលពាក់ព័ន្ធនឹងការឃោសនា ។ យើងត្រូវ បញ្ជាក់ឱ្យបានច្បាស់ចំពោះប្រព័ន្ធផ្សាយព័ត៌មាននានាថា ការសម្រេចចិត្តក្នុងការផ្សាយពាណិជ្ជកម្មឱ្យអង្គការមិនមែនរដ្ឋាភិបាល ។ល។ នឹងអាចធ្វើទៅបានលុះត្រាតែប្រព័ន្ធផ្សាយព័ត៌មាននោះមានទទួលខុសត្រូវ និងគោរពតាមក្រមសីលធម៌ ដែលមានក្នុងការផ្សព្វផ្សាយព័ត៌មាន និងមាតិកាផ្សេង ។

□□□

ឧបត្ថម្ភគាំទ្រពីស្ថានទូតអង់គ្លេសប្រចាំនៅទីក្រុងភ្នំពេញ
ដោយប្រើប្រាស់មូលនិធិយុទ្ធសាស្ត្ររបស់ FCO